ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៦

លេខៈ ១១

ឆ្នាំ២០១៨

# អារម្ភកថា

ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៦ នៅព្រះរាជាណាចក្រកម្ពុជា ទទួលបានជោគជ័យប្រកបដោយលទ្ធផល
ជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ដែលសម្រេចបានអត្រាកំណើនសេដ្ឋកិច្ចដ៏រឹងមាំក្នុងរយៈពេលទសវត្សរ៍ចុងក្រោយ
នេះ ដោយអត្រាកំណើនជាមធ្យមក្នុងរង្វង់**៧%**។ ផ.ស.ស សម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី ១ ២១៥
ដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ដល់ ១ ៣០២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៦។ ទន្ទឹមនេះ អតិផរណាមធ្យមប្រចាំឆ្នាំ
បានកើនឡើងបន្តិចពី១,២% ក្នុងឆ្នាំ២០១៥ ដល់៣% ក្នុងឆ្នាំ២០១៦ និងអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំអាចរក្សា
បានក្នុងកម្រិត៤ ០៥៦រៀល ក្នុងមួយដុល្លារអាមេរិក។ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០១៦ ត្រូវបានទ្រទ្រង់ដោយ
វិស័យសំខាន់ៗបី រួមមាន៖ (១)-វិស័យកសិកម្មសម្រេចបានកំណើន១,៨% (២)-វិស័យឧស្សាហកម្មមានកំណើន
ថមថយបន្តិចពី១១,៧% ក្នុងឆ្នាំ២០១៥ មកត្រឹម១០,៥% ក្នុងឆ្នាំ២០១៦ និង(៣)-វិស័យសេវាកម្មក៏សម្រេច
បានកំណើនថមថយបន្តិចពី៧,១% ក្នុងឆ្នាំ២០១៥ មកត្រឹម៦,៧% ក្នុងឆ្នាំ២០១៦។ រាជរដ្ឋាភិបាលកម្ពុជាបន្ត
អនុវត្តនូវគោលនយោបាយអាទិភាពរបស់ខ្លួនប្រកបដោយជោគជ័យដែលឆ្លុះបញ្ចាំងតាមរយៈ ១-ធានាសម្រេច
ឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង
ស្ថិរភាពហិរញ្ញវត្ថុក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព ២-ធានាការពារ
អធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសុខសន្តិភាព សន្តិសុខ ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់
សាធារណៈសង្គម ៣-បន្តធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព
ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់
វណ្ណៈនៃប្រជាជន ៤-ជំរុញអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (២០១៤-២០១៨) ៥-បន្តផ្តល់
អាទិភាពដល់ការតម្លើងប្រាក់បៀវត្សមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង
១ លានរៀល នៅឆ្នាំ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និងការកែទម្រង់រដ្ឋបាលសាធារណៈ
ពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២០១៥-២០១៨) ការកែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ៦-បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈ
ការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ព្រមទាំងការលើកកម្ពស់សេវា
សុខាភិបាល ៧-បន្តជំរុញការលើកទឹកចិត្តក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ
៨-បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាសម្រាប់គាំទ្រដល់
កំណើន និងការអភិវឌ្ឍ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង
បង្កើតបរិស្ថានអនុគ្រោះដល់ការអភិវឌ្ឍវិស័យឯកជន ក្នុងនោះរួមទាំងការលើកកម្ពស់យន្តការភាពជាដៃគូរវាង
វិស័យសាធារណៈ និងឯកជន ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និងបង្កើតការងារ ៩-ធានាការអនុវត្តគោល
នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ប្រកបដោយប្រសិទ្ធភាព ១០-បន្តជំរុញការ
អភិវឌ្ឍវិស័យហិរញ្ញវត្ថុ ជាពិសេសការត្រួតពិនិត្យក្នុងវិស័យធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុដោយធ្វើការតាមដាន
និងធ្វើអប្បមាទជាប្រចាំលើកំណើនឥណទាន និងការវិវត្តនៃវិស័យអចលនទ្រព្យ និងជំរុញការផ្តល់ឥណទានដល់
វិស័យកសិកម្ម និងសហគ្រាសធុនតូច និងមធ្យមជាដើម ១១-បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេស
បន្តលើកកម្ពស់ផលិតកម្មស្រូវ និងការនាំចេញអង្ករ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងផលិតកម្មម្ហូបអាហារ
១២-ពង្រឹង និងពង្រីកលំហាថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗ
ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសដើម្បីបង្កើនប្រាក់បញ្ញើរដ្ឋ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើ
ហិរញ្ញប្បទានក្រៅប្រទេស ១៣-បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈឱ្យស្ថិតក្នុង

កម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព ១៤-បន្តពង្រឹងស្ថាប័នសាធារណៈ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ហើយផ្តល់ឱកាសស្មើគ្នា និងប្រកបដោយសមធម៌ និង ១៥-លើកកម្ពស់គុណភាព ពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ។ ទាំងនេះបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយមោះមុត ឈ្លាសវៃ និងភ្លឺស្វាងរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយសារតែរាជរដ្ឋាភិបាលមានច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ព្រមទាំងបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមអាទិភាពគោលនយោបាយសំខាន់ៗខាងលើ។ ជាសក្ខីភាពនាំមកនូវចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៦ កើនឡើង ១៦,៦% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥ ចំណូលសារពើពន្ធកើនឡើង ១៥,៧% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥ ចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០១៦ កើនឡើង ៥,៨៩ % បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥ និងចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១៦ កើនឡើង ១៧,៩៣ % បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥ សំដៅបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាលំដាប់។ រីឯចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៦ អនុវត្តបានកើនឡើង ១៥,៥% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥ ចំណាយថវិការាជធានី ខេត្ត អនុវត្តបានកើនឡើង ៥,៦៧% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥ និងចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានកើនឡើង ២០,១៦% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥។ ការអនុវត្តចំណូល និងចំណាយនេះបានធ្វើឱ្យមានការសន្សំអតិរេកថវិកាថ្នាក់ជាតិចំនួន ១ ៥៨៨ ១៦២,៥លានរៀល។ ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ បានដើរតួជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាពសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ និងបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សាស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, ការបន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ, ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងការធានាបាននូវភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវ័ន្តនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងការកាត់បន្ថយភាពក្រីក្រ។

ថវិកាឆ្នាំ២០១៦ បានជួយបង្កើនល្បឿននៃការដោះស្រាយបញ្ហា ក៏ដូចជាការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ពិសេសការបន្តតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការទូទៅ និងការផ្តល់នូវមធ្យោបាយនិងធនធានសមស្របដល់ក្រសួង ស្ថាប័ន ដើម្បីចូលរួមលើកកម្ពស់សេវាសាធារណៈ ព្រមទាំងបន្តគាំទ្រការវិនិយោគចាំបាច់នានា ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និងផ្តល់លទ្ធផលជូនប្រជាជនគ្រប់ស្រទាប់វណ្ណៈ។

សរុបមក ថវិកាឆ្នាំ២០១៦ អាចប្រសិទ្ធនាមបានថាជា "**ថវិកានៃការប្រមូលពួតផ្តុំកម្លាំង និងធនធានសំដៅសម្រេចបាននូវសមិទ្ធផលសំខាន់ៗបន្ថែមទៀត ដើម្បីធានាបាននូវដំណើរការផ្លាស់ប្តូរមួយ ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព ដោយផ្សារភ្ជាប់ការគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ច និងការបែងចែកផលនៃកំណើននេះ ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា និងនិន្នាការពិភពលោក និងតំបន់ ដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅកាន់ត្រើយសុខសន្តិភាពយូរអង្វែង វិបុលភាព និងយុត្តិធម៌សង្គម**"។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍

ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០១៦ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្រ២០១២-២០១៦របស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀតដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) ស្ថាប័នសវនកម្មកំពូលប្រទេសស៊ុយអែត ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានាដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរសវនកម្មជាតិនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រឡាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ អង្គារ ៦ កើត ខែ ផល្គុន ឆ្នាំ រកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៨

**អគ្គសវនករ**

**សោម គីមសួគ៌**

# មាតិកា


**សេចក្ដីសង្ខេប** ........ ១

**១. សេចក្ដីផ្ដើម** ........ ៤

**១.១. លក្ខណៈទូទៅ** ........ ៤

**១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម** ........ ៤

**១.៣. គោលបំណងនៃការផ្សព្វផ្សាយ** ........ ៥

**២. ការគ្រប់គ្រងថវិកា** ........ ៥

**២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា** ........ ៥

**២.២.កិច្ចប្រតិបត្តិការថវិកា** ........ ៦

**៣. លទ្ធផលសវនកម្ម** ........ ៧

**៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ** ........ ៧

៣.១.១. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន ........ ៧

៣.១.២. ការគ្រប់គ្រងអ្នកជាប់ពន្ធ ........ ៨

៣.១.៣. វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណមានលក្ខណៈមិនសមស្រប ........ ៨

៣.១.៤. ការកំណត់តម្លៃពិន័យលើទំនិញល្មើសច្បាប់គយ ........ ១០

៣.១.៥. ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ........ ១១

៣.១.៦. ការរក្សាចំណូលពីការចុះបញ្ជីស្លាកសញ្ញាខ្មែរ និងបរទេសមិនបង់ចូលថវិការដ្ឋ ........ ១១

៣.១.៧. ការមិនទាន់បានប្រមូលចំណូលពីការចុះបញ្ជីលើកដំបូង និងបន្តសុពលភាព សម្រាប់ក្រុមជាងសំណង់ ........ ១១

៣.១.៨. ការកត់ត្រាចំណូលមិនត្រឹមត្រូវតាមការិយបរិច្ឆេទ ........ ១២

៣.១.៩. ការរក្សាសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់ ........ ១៣

៣.១.១០.ការមិនទាន់បានប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្ម ........ ១៣

៣.១.១១.ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ........ ១៤

៣.១.១២.ភាពយឺតយ៉ាវក្នុងការទូទាត់ចំណាយពីការដកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី ........ ១៥

៣.១.១៣.ការអនុវត្តចំណាយមុនការសម្រេច និងឯកភាពពីប្រធានអង្គភាពថវិកា ........ ១៦

៣.១.១៤.ការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៦ ........ ១៧

៣.១.១៥.ការបំបែកគម្រោងលទ្ធកម្មសាធារណៈ ........ ១៨

៣.១.១៦.ការពុំមានបញ្ជីបេឡាសម្រាប់កត់ត្រាតាមដានចំណូល-ចំណាយថវិកា ........ ១៩

៣.១.១៧.ភាពយឺតយ៉ាវក្នុងការរៀបចំផ្គូផ្គងរបាយការណ៍សម្រេចទូទាត់ថវិកា ចំណូល-ចំណាយប្រចាំឆ្នាំ ........ ១៩

៣.១.១៨.ភាពយឺតយ៉ាវក្នុងការប្ដូរស្លាកលេខរថយន្ត ........ ២០

៣.១.១៩.បំណុលកើនឡើងដោយមិនមានវិធានការតឹងទារ ........ ២១

**៣.២.ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** ........ ២១
៣.២.១. ការប្រមូលពន្ធប្រថាប់ត្រា........ ២១
៣.២.២. ការចេញវិញ្ញាបនប័ត្របញ្ជាក់អនាម័យពុំទាន់អស់លទ្ធភាព........ ២២
៣.២.៣. ការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុលពុំទាន់អស់លទ្ធភាព........ ២៣
៣.២.៤. ការអនុវត្តកិច្ចលទ្ធកម្ម និងការប្រគល់ទទួលចុងឆ្នាំរបស់រាជធានី ខេត្ត........ ២៤
៣.២.៥. ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ........ ២៤
៣.២.៦. កង្វះខាតក្នុងការរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ........ ២៥
៣.២.៧. ភាពយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ........ ២៥
**៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម**........ ២៦
៤.១. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ........ ២៧
៤.២. ការបំពេញកាតព្វកិច្ចសារពើពន្ធ........ ២៧
៤.៣. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ........ ២៨
៤.៤. ការប្រើប្រាស់វិក្កយបត្រ........ ២៨
៤.៥. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ........ ២៨
៤.៦. ការប្រមូលពន្ធអចលនទ្រព្យ........ ២៩
៤.៧. ការកត់ត្រាចំណូលថវិការដ្ឋ........ ២៩
៤.៨. ការទូទាត់ និងការកត់ត្រាចំណាយ........ ២៩
៤.៩. ការធ្វើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ........ ៣០
៤.១០.ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ........ ៣០
៤.១១.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ........ ៣០
**៥.សេចក្តីសន្និដ្ឋាន**........ ៣០

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១៦


## សេចក្ដីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០១៦ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្ដាក្រសួងស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **១៨ ៥១៥ ៧០៧,៩**លានរៀល ស្មើនឹង**២២,៩៨%** នៃ ផ.ស.ស គឺបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៥,១%** បានកើនឡើង **១៤,១%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥។ ទាំងនេះឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ ជាពិសេសវិធានការដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ក្នុងការពង្រឹងរដ្ឋបាលប្រមូលចំណូល និងគោលនយោបាយ។ ចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អតាមរយៈការអនុវត្តផែនការសកម្មភាពជាក់លាក់ក្នុងការពង្រឹងរដ្ឋបាល និងគោលនយោបាយគយ និងការលើកកម្ពស់អភិបាលកិច្ចអង្គភាពគយ និងរដ្ឋាករដែលត្រូវដាក់ចេញ និងការអនុវត្តវិធានការនៃការប្រមូលចំណូលគយ និងរដ្ឋាករតាមរយៈការពង្រឹងអនុលោមភាពមួយចំនួន។ ជាមួយគ្នានេះ ចំណូលពន្ធដារក៏ទទួលបានលទ្ធផលល្អប្រសើរ តាមរយៈការកែលម្អគោលនយោបាយសារពើពន្ធ ពង្រឹងរដ្ឋបាលសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អក្នុងគោលដៅបង្កើនចំណូលពន្ធ ធ្វើឱ្យប្រព័ន្ធពន្ធមានភាពសាមញ្ញ មានសមធម៌ និងយុត្តិធម៌ មានស្ថិរភាព មានតម្លាភាព មានប្រសិទ្ធភាព និងបន្ថយអំពើគេចវេះពន្ធ។

**ការកែលម្អគោលនយោបាយសារពើពន្ធត្រូវបានអនុវត្ត** មានជាអាទិ៍៖ (១)-ការកែប្រែរបបកំណត់ពន្ធដោយលុបចោលរបបម៉ៅការ និងរបបបំពេញ មកជារបបស្វ័យប្រកាសតែមួយ និងបែងចែកអ្នកជាប់ពន្ធជាបីប្រភេទគឺ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ (២)-ការកំណត់វិធានគណនេយ្យសម្រាប់អ្នកជាប់ពន្ធតាមចំណាត់ថ្នាក់នីមួយៗ (៣)-ការកែសម្រួលប្រាក់ពន្ធប៉ាតង់សម្រាប់អ្នកជាប់ពន្ធតាមចំណាត់ថ្នាក់នីមួយៗ (៤)-ការលុបចោលការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងគ្រឿងចក្រប្រហាក់ប្រហែល និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ (៥)-ការកែសម្រួល និងកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះចំពោះរថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្ដោងដែលជាប្រភេទរថយន្តធុនធ្ងន់ (៦)-ការកែសម្រួលការប្រមូលពន្ធប្រថាប់ត្រាដោយលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលទ្រព្យក្នុងរង្វង់ញាតិរវាងឪពុក-ម្ដាយ

បង្កើត និងកូនបង្កើត រវាងប្តីប្រពន្ធ និងរវាងយាយតាបង្កើតចៅបង្កើត និងលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ(៧)-ការអនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាសដែលអនុវត្តពហុគម្រោង (៨)-ការអនុញ្ញាតសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យចំពោះធនាគារក្នុងស្រុក (៩)-ការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សា (១០)-ការអនុវត្តការលើកលែងអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ (១១)-ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ (១២)-ការរៀបចំកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និង(១៣)-រៀបចំបទដ្ឋានគតិយុត្តបំពេញបន្ថែមផ្សេងទៀត ដើម្បីផ្តល់ភាពងាយស្រួលក្នុងការអនុវត្តច្បាប់។

**វិធានការពង្រឹងរដ្ឋបាលសារពើពន្ធសំខាន់ៗក្នុងការប្រមូលចំណូលពន្ធដារ** មានជាអាទិ៍៖ (១)-ពន្លឿនការដោះស្រាយវិវាទសារពើពន្ធកម្រិតអគ្គនាយកដ្ឋានពន្ធដារ (២)-ការកំណត់បំណុលពន្ធមិនអាចប្រមូលបាន និងអនុវត្តការបង់បំណុលតាមដំណាក់កាល (៣)-ការអង្កេតសហគ្រាសនៅរាជធានីភ្នំពេញដើម្បីជំរុញការចុះបញ្ជីសហគ្រាស (៤)-ជំរុញការបិទតែមប្រើអាករលើផលិតផលជាប់អាករពិសេស (៥)-ជំរុញការអនុវត្តវិធានវិក្កយបត្រ (៦)-ជំរុញការអនុវត្តកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស (៧)-ពង្រឹងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងពន្ធប្រថាប់ត្រា (៨)-ពង្រឹងការធ្វើសវនកម្មនិងពង្រឹងនីតិវិធីនៃការទារបំណុលពន្ធ (៩)-ពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ (១០)-សាមញ្ញភាវូបនីយកម្មនៃការចុះបញ្ជីពន្ធដារ (១១)-ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រងទិន្នន័យចំណូលពន្ធ និង(១២)-ពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងការទទួលប្រាក់ពន្ធគ្រប់ប្រភេទ។

**វិធានការអភិបាលកិច្ចល្អក្នុងការប្រមូលចំណូលពន្ធដារ** មានជាអាទិ៍៖ (១)-ពង្រឹងធនធានមនុស្ស និងពង្រឹងអភិបាលកិច្ច ដោយបានធ្វើការបណ្តុះបណ្តាលមន្ត្រីពន្ធដារជាច្រើន និងបានធ្វើការលើកទឹកចិត្តដល់មន្ត្រីមានស្នាដៃ និងដាក់ទោសទណ្ឌចំពោះមន្ត្រីប្រព្រឹត្តខុស និង(២)-ពង្រឹងការផ្តល់សេវាកាន់តែល្អប្រសើរជូនអ្នកជាប់ពន្ធ តាមរយៈការផ្លាស់ប្តូរផ្នត់គំនិតមន្ត្រីពន្ធដារលើការត្រួតត្រាទៅជាអ្នកផ្តល់សេវា។

រីឯចំណូលមិនមែនសារពើពន្ធ ក៏សម្រេចបានលទ្ធផលល្អប្រសើរផងដែរ តាមរយៈការកែលម្អគោលនយោបាយចំណូលមិនមែនសារពើពន្ធ ប៉ុន្តែនៅមានបញ្ហាប្រឈមដោយសារការគ្រប់គ្រងចំណូលនេះពាក់ព័ន្ធនឹងសមត្ថកិច្ចខុសៗគ្នា និងវិស័យជាច្រើន។

តាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានការកត់សំគាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតមានជាអាទិ៍៖ (១)-ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន (២)-ការគ្រប់គ្រងអ្នកជាប់ពន្ធ (៣)-វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណមានលក្ខណៈមិនសមស្រប (៤)-ការកំណត់តម្លៃពិន័យលើទំនិញល្មើសច្បាប់គយ (៥)-ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ (៦)-ការរក្សាចំណូលពីការចុះបញ្ជីស្លាបត្យាករខ្មែរ និងបរទេសមិនបង់ចូលថវិការដ្ឋ (៧)-ការមិនទាន់បានប្រមូលចំណូលពីការចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ (៨)-ការកត់ត្រាចំណូលមិនត្រឹមត្រូវតាមការិយបរិច្ឆេទ (៩)-ការរក្សាសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់ (១០)-ការមិនទាន់បានប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្ម (១១)-ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម (១២)-ការកាន់កាប់កិច្ចបញ្ជីគណនេយ្យរបស់អ្នកជាប់ពន្ធ (១៣)-ការបំពេញកាតព្វកិច្ចសារពើពន្ធ (១៤)-របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ (១៥)-ការប្រើប្រាស់វិក្កយបត្រ និង(១៦)-ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន**១៦ ៩២៧ ៥៤៥,៤**លានរៀល ស្មើនឹង **២១,០១%** នៃផ.ស.ស គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **៣,៥%** ហើយបានកើនឡើង **១៥,៥%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៥។

ការអនុវត្តគោលនយោបាយចំណាយថវិកាឆ្នាំ២០១៦ ទទួលបានលទ្ធផលល្អ គឺ ៩៦,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ដោយបានបំពេញតួនាទីជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព ដោយដោះស្រាយបាននូវអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមការគ្រោងទុក ឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ចំពោះមុខ និងគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេស ទី១-សម្រេចបានការអនុវត្តគោលនយោបាយតម្លើងបៀវត្សជូនមន្ត្រីរាជការ ទី២-បង្កើតនូវប្រសិទ្ធភាពចំណាយតាមរយៈវិធានការបង្កើនប្រសិទ្ធភាពក្នុងការវិភាជន៍ និងក្នុងការពិនិត្យផ្តល់ធានាចំណាយ ដោយធានាបាននូវចំណាយចំមុខសញ្ញា មានភាពចាំបាច់ ថ្លៃសមរម្យ បរិមាណត្រឹមត្រូវ គុណភាពសមរម្យ និងទាន់ពេលវេលា ទី៣-នៅក្នុងវិស័យរដ្ឋបាលទូទៅ ការអនុវត្តចំណាយជាទូទៅមានលក្ខណៈប្រសើរ។ លម្អៀងបន្តិចបន្តួចគឺលទ្ធផលនៃការពង្រឹងប្រសិទ្ធភាពចំណាយ និងការគ្រោងថវិកាលម្អៀង ជាពិសេសចំណាយបេសកកម្មក្នុង និងក្រៅប្រទេស ទី៤-នៅក្នុងវិស័យការពារជាតិ និងសន្តិសុខ ការអនុវត្តបានសម្រេចបានលទ្ធផលល្អប្រសើរ ជាមួយនឹងការសន្សំសំចៃថវិកា និងការបង្វែរទៅរកអាទិភាពកើតឡើងថ្មីៗនៅក្នុងឆ្នាំ ទី៥-នៅក្នុងវិស័យសង្គមកិច្ច ការអនុវត្តបានកែលម្អច្រើននៅឆ្នាំ២០១៦ ទី៦-ក្នុងការអនុវត្តចំណាយក្នុងវិស័យសេដ្ឋកិច្ចបានកែលម្អប្រសើរជាងមុន ទី៧-ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឆ្នាំ២០១៦ រាជរដ្ឋាភិបាលសន្សំសំចៃថវិកាបានមួយចំនួន ទី៨-យន្តការផ្ទេរមុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ជាតិឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈក្រសួងមួយចំនួនកំពុងដំណើរការអនុវត្ត ទី៩-ឱនភាពទូទៅនៃថវិកាត្រូវបានរក្សាកាត់បន្ថយឱ្យមកស្ថិតនៅក្នុងកម្រិតដែលអាចធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការគ្រប់គ្រងបំណុលសាធារណៈក្រៅប្រទេសតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ របស់រាជរដ្ឋាភិបាល។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា (១)-ភាពយឺតយ៉ាវក្នុងការទូទាត់ចំណាយពីការដកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី (២)-ការអនុវត្តចំណាយមុនការសម្រេច និងឯកភាពពីប្រធានអង្គភាពថវិកា (៣)-ការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៦ (៤)-ភាពយឺតយ៉ាវក្នុងការរៀបចំផ្គូផ្គងរបាយការណ៍សម្រេចទូទាត់ថវិកាចំណូល-ចំណាយប្រចាំឆ្នាំ (៥)-ការកត់ត្រាចំណូលថវិការដ្ឋ (៦)-ការទូទាត់ និងការកត់ត្រាចំណាយ និង(៧)-ការផ្ញើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន **៣ ៨៣១ ២៥០,២** លានរៀល ស្មើនឹង**៩៩,០%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន **៣ ៨៧១ ៣៥០,០**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន **៤០ ០៩៩,៨** លានរៀល។

### ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**៩៤៨ ៤៥០,០**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ ចំនួន**៣,៧%** និងការអនុវត្តចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបាន**៩៤៦ ៤៥៥,១**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ ចំនួន**៣,៥%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបាន **១១៩ ៥៨០,៣**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ ចំនួន**៧,៣%** និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបាន**១១៧ ៩៩៩,៥**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ ចំនួន**៥,៥%**។ រីឯចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបាន **៣៩៧ ៩២៤,៥** លានរៀលគឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ

២០១៦ ចំនួន**២៩,០%** និងចំណាយចរិការបស់រដ្ឋបាលឃុំ សង្កាត់អនុវត្តបាន**៣១២ ៤០៣,៩**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ ចំនួន **១,៣%**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ដូចជា (១)-ការប្រមូលពន្ធប្រថាប់ (២)-ការចេញវិញ្ញាបនប័ត្របញ្ជាក់អនាម័យពុំទាន់អស់លទ្ធភាព (៣)-ការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុលពុំទាន់អស់លទ្ធភាព (៤)-ការអនុវត្តកិច្ចលទ្ធកម្ម និងការប្រគល់ទទួលចុងឆ្នាំរបស់រាជធានី ខេត្ត (៦)-ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ (៧)-កង្វះខាតក្នុងការរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ (៨)-ភាពយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ និង(៩)-ការប្រមូលពន្ធអចលនទ្រព្យ។

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាស និងសារាចរណែនាំត្រើនរំលឹកជាញឹកញាប់ឱ្យក្រសួង ស្ថាប័ន និងសាលារាជធានី ខេត្តធ្វើការផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ ដោយអនុវត្តបានមួយចំនួនធំ និងនៅមានខ្វះខាតមួយចំនួនតូច។ ចំពោះការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិវិញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៦ ទ្រព្យសម្បត្តិរដ្ឋមួយចំនួនតូចនៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

# ១. សេចក្តីផ្តើម

## ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ច អនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រងការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

## ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០១៦ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០១៦ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបចំនួន៧៦ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដក ស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះសំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួងស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១៦ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/ ១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៦ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូលចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ២០១៦ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូល** | **១៧ ៦១២ ៤៧៧,0** | **១៨ ៥១៥ ៧០៧,៩** | **១០៥,១%** |
| -ចំណូលចរន្ត | ១៣ ៤០៧ ២៦៣,0 | ១៤ ២៧៧ ៦២២,៦ | ១០៦.៥% |
| -ចំណូលមូលធនក្នុងប្រទេស | ១៣០ ៨៦៤,0 | ១១៩ ៨៩៩,៧ | ៩១,៦% |
| -ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២០៣ 000,0 | ២៨៦ ៩៣៥,៤ | ១៤១,៣% |
| -ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៨៧១ ៣៥០,0 | ៣ ៨៣១ ២៥០,២ | ៩៩,0% |
| **II. សរុបចំណាយ** | **១៧ ៥៤៤ ៤៧៧,0*** | **១៦ ៩២៧ ៥៤៥,៤** | ៩៦,៥% |
| -ចំណាយចរន្ត | ១១ ២៣៨ ៩៨៩,0* | ១០ ៨៧៦ ៣៨៩,0 | ៩៦,៨% |
| -ចំណាយមូលធន | ២ ៤៣៤ ១៣៨,0 | ២ ២១៩ ៩០៦,២ | ៩១,២% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៨៧១ ៣៥០,0 | ៣ ៨៣១ ២៥០,២ | ៩៩,0% |

### ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

#### ខ₁/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ២០១៦ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៩១៤ ៦៣៥,0** | **៩៤៨ ៤៥០,0** | **១០៣,៧%** |
| -ចំណូលចរន្ត | ៨០៨ ៨៩៤,0 | ៧៩៥ ៧២៨,0 | ៩៨,៤% |
| •ចំណូលសារពើពន្ធ | ៧៧៧ ៥០៤,0 | ៧៥៥ ២៥៨,១ | ៩៧,១% |
| •ចំណូលមិនមែនសារពើពន្ធ | ៣១ ៣៩០,0 | ៤០ ៤៦៩,៩ | ១២៨,៩% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ១០៥ ៧៤១,0 | ១៥២ ៧២២,0 | ១៤៤,៤% |
| **II. សរុបចំណាយថវិកា** | **៩១៤ ៦៣៥,0** | **៩៤៦ ៤៥៥,១** | **១០៣,៥%** |
| -ចំណាយចរន្ត | ៧៥១ ៧៣០,0 | ៧៥៩ ៨៨៣,៣ | ១០១,១% |
| -ចំណាយមូលធន | ១៦២ ៩០៥,0 | ១៨៦ ៥៧១,៨ | ១១៤,៥% |

---

* តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន ៨២ 000លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

### ខ២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ២០១៦ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **១១១ ៤៨០,0** | **១១៩ ៥៨០,៣** | **១០៧,៣%** |
| -ចំណូលចរន្ត (មិនមែនសារពើពន្ធ) | ១២ ៣៤៨,0 | ១៧ ០៦១,៦ | ១៣៨,២% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៩៩ ១៣២,0 | ៩៨ ៩៨៥,0 | ៩៩,៩% |
| -អតិរេកឆ្នាំ២០១៥ | | ៣ ៥៣៣,៧ | |
| **II. សរុបចំណាយថវិកា** | **១១១ ៤៨០,0** | **១១៧ ៥៩៩,៥** | **១០៥,៥%** |
| -ចំណាយចរន្ត | ១១១ ៤៨០,0 | ១១៧ ៥១៥,៧ | ១០៥,៤% |
| -ចំណាយមូលធន | | ៨៣,៨ | |

### ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ២០១៦ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៣០៨ ៤១០,0** | **៣៩៧ ៩២៤,៥** | **១២៩,0%** |
| -ចំណូលមិនមែនសារពើពន្ធ | 0 | ៨ ៧៦៦,៥ | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិ | ៣០៨ ៤១០,00 | ៣០៨ ៤១០,00 | ១00,0% |
| -អតិរេកឆ្នាំ២០១៥ | 0 | ៨0 ៧៤៨,0 | |
| **II. សរុបចំណាយថវិកា** | **៣០៨ ៤១០,0** | **៣១២ ៤០៣,៩** | **១០១,៣%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ២0 ៦១១,២ | ២១ ៦៧៨,៧ | ១០៥,២% |
| -ចំណាយសង្កាត់ចំណុះក្រុង | ២៤ ៣៧៦,២ | ២៦ ២៩៦,១ | ១០៧,៩% |
| -ចំណាយឃុំ | ២៦៣ ៤២២,៦ | ២៦៤ ៤២៩,១ | ១00,៤% |

# ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៩៦០ សហវ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យនៃអគ្គនាយកដ្ឋានពន្ធដារ ត្រង់ប្រការ៨ បានចែងថា "ការិយាល័យប្រមូលព័ត៌មានអ្នកជាប់ពន្ធមានភារកិច្ចរៀបចំ និងគ្រប់គ្រងឯកសារ លិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធមានភារកិច្ចរៀបចំ និងគ្រប់គ្រងឯកសារ លិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ... ប្រមូលព័ត៌មានសហគ្រាសដែលបានចុះបញ្ជីតាមក្រសួងស្ថាប័ននានា ជូនទៅនាយកដ្ឋាននានា និងសាខាពន្ធដារខេត្ត ខណ្ឌ..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ប៉ុន្តែ អគ្គនាយកដ្ឋានពន្ធដារមិនទាន់បានប្រមូលព័ត៌មានសហគ្រាសដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័នមួយចំនួនទៀត។ ការខកខានក្នុងការប្រមូលព័ត៌មានអំពីសហគ្រាសដែលបានចុះបញ្ជីនៅតាមក្រសួង ស្ថាប័ន នាំឱ្យនាយកដ្ឋាននានា និងសាខាពន្ធដារខេត្ត ខណ្ឌ ដែលជាអង្គភាពអនុវត្តការប្រមូលពន្ធមិនមានព័ត៌មាន អំពីអ្នកជាប់ពន្ធដែលខ្លួនគ្រប់គ្រង ដើម្បីពិនិត្យបញ្ជាក់លើការប្រកាសបង់ពន្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យពង្រឹងការអនុវត្តតួនាទីប្រមូលព័ត៌មានសហគ្រាសដែលបានចុះបញ្ជីតាមក្រសួងស្ថាប័ននានា ដើម្បីឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានធ្វើការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងបានបង្កើតក្រុមការងារមួយចំនួនរួចមកហើយ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងផ្ទៀងផ្ទាត់ ក៏ដូចជាប្រមូលព័ត៌មានរបស់អ្នកជាប់ពន្ធ ដើម្បីពិនិត្យបញ្ជាក់លើការបំពេញកាតព្វកិច្ចពន្ធដាររបស់អ្នកជាប់ពន្ធ។

### ៣.១.២. ការគ្រប់គ្រងអ្នកជាប់ពន្ធ

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់បេសកកម្មជូនអគ្គនាយកដ្ឋានពន្ធដារក្នុងការប្រមូលចំណូលសារពើពន្ធតាមរយៈអនុក្រឹត្យលេខ៤៨៨ អនក្របក. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ត្រង់មាត្រា ៣៥ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចដូចជា៖ ផ្តល់សេវាដល់អ្នកជាប់ពន្ធ ប្រមូលចំណូលពន្ធ និងអនុវត្តកម្មវិធីចាប់បង្ខំចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។ ផ្អែកតាមស្ថិតិសហគ្រាសប្រចាំខែធ្នូ ឆ្នាំ២០១៦ របស់ការិយាល័យស្ថិតិសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សហគ្រាសមួយចំនួនតូច ពុំបានដាក់លិខិតប្រកាសទេ។

ការខកខានរបស់អ្នកជាប់ពន្ធក្នុងការដាក់លិខិតប្រកាសពន្ធទៅតាមទម្រង់ និងទីកន្លែងកំណត់ បានផ្តល់ផលលំបាកចំពោះរដ្ឋបាលសារពើពន្ធក្នុងការប្រមូលពន្ធ និងជាបច្ច័យមួយនៃការគេចវេសពន្ធ។ ដើម្បីពង្រឹងការប្រមូលចំណូលពន្ធពីសហគ្រាស ដែលគេចវេះពន្ធ អគ្គនាយកដ្ឋានពន្ធដារគួរមានវិធានការឱ្យបានម៉ឺងម៉ាត់បន្ថែមទៀតចំពោះសហគ្រាស ដែលមិនបានមកដាក់លិខិតប្រកាស និងសហគ្រាសដែលបាត់ខ្លួន។

ឆ្លើយតបទៅនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា ក្នុងចំណោមសហគ្រាស ដែលមិនបានមកដាក់លិខិតប្រកាស គឺរួមមានទាំងសហគ្រាសដែលបាត់ខ្លួនផងដែរ ទើបធ្វើឱ្យតួលេខបញ្ជីអ្នកជាប់ពន្ធខ្ពស់។ បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារបានបង្កើតនូវប្រព័ន្ធ Auto Printout ដើម្បីព្រីនលិខិតជូនដំណឹងសម្រាប់អ្នកជាប់ពន្ធ ដែលខកខានមិនបានបំពេញកាតព្វកិច្ចសារពើពន្ធទាន់ពេលវេលា និងដើម្បីធ្វើការចែកជូនទៅដល់ក្រុមហ៊ុន សហគ្រាសទាំងនោះឱ្យមកបំពេញកាតព្វកិច្ចសារពើពន្ធ។ ក្រោយពីចេញលិខិតរំលឹករួចហើយ ក្រុមហ៊ុនសហគ្រាសទាំងនោះ នៅតែមិនចូលខ្លួនមកបំពេញកាតព្វកិច្ចសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារនឹងចាត់វិធានការ ដោយធ្វើការដកហូតវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាដើម។ល។

### ៣.១.៣. វិក្កយបត្រ បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណមានលក្ខណៈមិនសមស្រប

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា(នាយកដ្ឋានផែនការបច្ចេកទេស និងកិច្ចការអន្តរជាតិ)មានតួនាទី និងភារកិច្ចក្នុងការស្រាវជ្រាវ និងកែសម្រួលជាប្រចាំនូវបញ្ជីតម្លៃគិតពន្ធ ឬអាករគយសម្រាប់ពិចារណាលើទំនិញនាំចេញ នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់ឱ្យបានសមស្របតាម

ភាពជាក់ស្តែង សម្រាប់ជាមូលដ្ឋានពិចារណានិងសម្រេចចិត្ត ក្នុងការអនុវត្តការងាររបស់អង្គភាពគយ និងរដ្ឋាករមូលដ្ឋាន។

តាមការធ្វើតេស្តលើឯកសារស្នើសុំកំណត់តម្លៃគិតពន្ធនាំចូលនៅនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិមានកង្វះខាតក្នុងការពិនិត្យមើលឯកសារភ្ជាប់សម្រាប់ការកំណត់តម្លៃគិតពន្ធដូចជា៖ វិក្កយបត្រ និងអញ្ញត្តិប័ណ្ណប្រកាសបរិមាណខុស វិក្កយបត្រ និងបញ្ជីវេចខ្ចប់ប្រកាសទម្ងន់គីឡូក្រាមខុស បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណប្រកាសគីឡូក្រាមខុសគ្នា វិក្កយប័ត្រ បញ្ជីវេចខ្ចប់និងអញ្ញត្តិប័ណ្ណប្រកាសបរិមាណ និងទម្ងន់ជាគីឡូក្រាមខុស វិក្កយប័ត្រ បញ្ជីវេចខ្ចប់ប្រកាស និងអញ្ញត្តិប័ណ្ណប្រកាសខ្វះបរិមាណ វិក្កយប័ត្រ បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណប្រកាសខ្វះមុខទំនិញ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា មានករណីខ្វះខាតខ្លះដូចការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិមែន ដោយសារមូលហេតុមួយចំនួនដូចជា៖ ការត្រួតពិនិត្យលម្អិតលើឯកសារត្រូវបានធ្វើឡើងតាមរយៈអភិក្រមនៃការគ្រប់គ្រងហានិភ័យ គឺមន្ត្រីគយធ្វើការត្រួតពិនិត្យលម្អិតតែលើឯកសារណា ដែលមានកម្រិតហានិភ័យខ្ពស់ចំពោះចំណូលប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនករណីដែលមានការខ្វះខាតនេះមានចំនួនតិចតួចប៉ុណ្ណោះបើធៀបទៅនឹងចំនួនសំណុំឯកសារសរុប។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

### ៣.១.៤. ការកំណត់តម្លៃពិន័យលើទំនិញល្មើសច្បាប់គយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការសម្រុះសម្រួលបទល្មើសគយ ដោយបញ្ជាក់ថា រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលដូចជា៖ប្រធានទីស្នាក់ការគយ និងរដ្ឋាករមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពីមួយលានប្រាំសែន(១ ៥០០ ០០០)រៀល។ ប្រធានការិយាល័យ ឬប្រធានសាខាគយ និងរដ្ឋាករមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពីបួនលាន (៤ ០០០ ០០០)រៀល អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទ។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានចេញលិខិត ស្តីពីការកែសម្រួលតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញនាំចូលមួយចំនួន ដោយបានបញ្ជាក់ក្នុងសេចក្តីណែនាំបន្ថែមថា៖ ចំពោះតម្លៃគិតពន្ធលើទំនិញល្មើសច្បាប់គយគ្រប់ប្រភេទ ត្រូវកំណត់ដោយបូកបន្ថែម៥០% (ហាសិបភាគរយ) លើតម្លៃគិតពន្ធគយ។

តាមការធ្វើតេស្តលើកំណត់ហេតុល្មើសច្បាប់គយនៅសាខាគយ និងរដ្ឋាករខេត្តប៉ៃលិន និងសាខាគយ និងរដ្ឋាករខេត្តបន្ទាយមានជ័យ (ការិយាល័យគយ និងរដ្ឋាករប៉ោយប៉ែត) អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាគយ និងរដ្ឋាករខេត្តប៉ៃលិនបានធ្វើសេចក្តីសម្រេចវិនិច្ឆ័យលើកំណត់ហេតុល្មើសច្បាប់គយចំនួន០៥ ដោយពុំបូកបន្ថែមតម្លៃគិតពន្ធ៥០%នៃតម្លៃទំនិញល្មើសទេ គឺបានបូកត្រឹមតែ២០%ប៉ុណ្ណោះ។ ចំពោះសាខាគយ និងរដ្ឋាករខេត្តបន្ទាយមានជ័យ (ការិយាល័យគយ និងរដ្ឋាករប៉ោយប៉ែត) បានធ្វើសេចក្តីសម្រេចវិនិច្ឆ័យលើកំណត់ហេតុល្មើសច្បាប់គយចំនួន០៧ ដោយកំណត់តម្លៃគិតពន្ធលើទំនិញល្មើសច្បាប់ (ទូរសព្ទដៃម៉ាកSamsung GalaxyJ7) ត្រឹម៦០

ដុល្លារ/កំប្លេរ ប៉ុន្តែតម្លៃចម្លងការចេញឱ្យអនុវត្តគឺតម្លៃ១៥០ដុល្លារ/កំប្លេរ ដែលការកំណត់តម្លៃនេះទាបជាងតម្លៃចម្លងការចំនួន៩០ដុល្លារ/កំប្លេរ ចំពោះទំនិញល្មើសច្បាប់គយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមទទួលស្គាល់នូវចំណុចខ្វះខាតខ្លះរបស់អង្គភាពគយ និងរដ្ឋាករមូលដ្ឋានតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ទន្ទឹមនឹងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមបំភ្លឺបន្ថែមថា៖ ការកំណត់សមត្ថកិច្ចដោះស្រាយបទល្មើសរបស់អង្គភាពគយ និងរដ្ឋាករមូលដ្ឋានបានកំណត់ជាប្រាក់រៀលតាំងពីឆ្នាំ២០០៩មកម្ល៉េះ ដែលគិតមកដល់បច្ចុប្បន្នហាក់ពុំសូវមានភាពសមស្រប ក្នុងន័យជំរុញការដោះស្រាយបទល្មើសឱ្យបានឆាប់រហ័ស ជាពិសេសចំពោះបទល្មើសតូចតាចដែលមិនសូវមានហានិភ័យខ្ពស់ដល់ចំណូលគយ ហើយមានទីតាំងនៅខេត្តឆ្ងាយៗ ការសម្របសម្រួលបទល្មើសក្នុងករណីខ្លះអាចមានភាពលម្អៀងខ្លះៗពីការកំណត់ក្នុងប្រកាសស្តីពីការសម្រុះសម្រួលបទល្មើស ព្រោះការតម្រូវឱ្យមកដោះស្រាយនៅទីចាត់ការកណ្តាលតម្រូវឱ្យមានការចំណាយលើសពីកម្រិតបទល្មើសផងក៏សឹងមាន។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

### ៣.១.៥. ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៦ បានបញ្ជាក់ថា ការិយបរិច្ឆេទនៃឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ការបិទបញ្ជីចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៦ ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ជាកំហិត។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) មានសមតុល្យតួលេខចំណូលមិនមែនសារពើពន្ធ (រដ្ឋបាលកណ្តាល) ចុងឆ្នាំ២០១៦មួយចំនួនមិនទាន់បានបង្វែរចូលថវិការដ្ឋនៅឡើយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមបំភ្លឺបន្ថែមថា ក្រសួងបានធ្វើការជំរុញ និងចាត់វិធានការជាបន្តបន្ទាប់ ដោយស្នើសុំឱ្យក្រសួង ស្ថាប័នប្រមូលចំណូល ធ្វើការបង់ចំណូលចូលគណនីទោលរបស់រតនាគារជាតិឱ្យបានទាន់ពេលវេលា ដូចជា ធ្វើជាលិខិតផ្លូវការ បង្កើតក្រុមការងារតាមប្រព័ន្ធ Telegram កំពុងរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដែលកំណត់ពីការពិន័យចំពោះការបង់ចំណូលយឺត និងកំពុងសហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដែលគ្រោងនឹងដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ខាងមុខ។ល។ បច្ចុប្បន្នទោះបីមានការខិតខំប្រឹងប្រែងជំរុញឱ្យមានការបង់ចំណូល ឱ្យទាន់ពេលវេលា ប៉ុន្តែនៅមានបញ្ហាស្មុគស្មាញជាច្រើន គឺដោយសារចំណូលត្រូវបានបង់ដោយក្រសួងស្ថាប័នប្រមូលចំណូល និងភាគីឯកជនផ្ទាល់តែម្តង។ ភាគីឯកជនខ្លះបង់ថវិកាចូលគណនីទោលរបស់រតនាគារជាតិដោយពុំមានព័ត៌មានពេញលេញ ដែលធ្វើឱ្យមានការយឺតយ៉ាវក្នុងការកត់ត្រាប្រភេទ និងប្រភពចំណូល។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

### ៣.១.៦. ការរក្សាចំណូលពីការចុះបញ្ជីស្ថាបត្យករខ្មែរ និងបរទេសមិនបង់ចូលថវិការដ្ឋ

ដើម្បីគ្រប់គ្រងការប្រមូលចំណូល និងការពង្រឹងការបង់ចំណូលចូលថវិការដ្ឋបានទាន់បាន ទាន់ពេលវេលាស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/ ០១៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ត្រង់មាត្រា២០ បានចែងថា " ចំណូលត្រូវកត់ត្រាចូលទាំងស្រុង ហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ។ ការបង្កើនដោយអាណាប័កនូវទឹកប្រាក់នៃឥណទានដែលបានអនុម័ត ដោយសម្អាងលើប្រាក់ចំណូលពិសេសណាមួយត្រូវបានហាមឃាត់ដាច់ខាត" ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គលេខាធិការដ្ឋានគណៈស្ថាបត្យករកម្ពុជាបានរក្សាចំណូលពីការចុះឈ្មោះជាស្ថាបត្យករចុះបញ្ជី និងប្រាក់វិភាគទានសិទ្ធិចុះឈ្មោះជាស្ថាបត្យករចុះបញ្ជីខ្មែរ និងបរទេសគិតចាប់ពីឆ្នាំ២០១៤រហូតមកត្រឹមឆ្នាំ២០១៦ដោយមិនទាន់ធ្វើការបង់ចំណូលចូលថវិការដ្ឋ។

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់គួរធ្វើការណែនាំដល់អគ្គលេខាធិការដ្ឋាន គណៈស្ថាបត្យករកម្ពុជានៃអគ្គនាយកដ្ឋានសំណង់ឱ្យធ្វើការបង់ចំណូលដែលប្រមូលបានចូលថវិការដ្ឋ ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងករណីនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងខិតខំជំរុញឱ្យអង្គភាពក្រោមឱវាទធ្វើការបង់ចំណូលចូលថវិការដ្ឋឱ្យបានទាន់ពេលវេលា។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងអនុវត្តការបង់ចំណូលចូលថវិការដ្ឋពីការប្រមូលចំណូលសេវាសាធារណៈឱ្យបានពេញលេញ និងទាន់ពេលវេលា។

### ៣.១.៧. ការមិនទាន់បានប្រមូលចំណូលពីការចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់ក្រុមជាងសំណង់

ដើម្បីពង្រឹងយន្តការប្រមូលចំណូលពីការចុះបញ្ជីដំបូង និងបន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ឱ្យកាន់តែមានប្រសិទ្ធភាពនោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញនូវប្រកាសរួមលេខ៩៩៥សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ៩៩៥ សហវ. ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ត្រង់ចំណុទី III ការចុះបញ្ជីសហគ្រាស-ក្រុមហ៊ុនប្រកបអាជីវកម្មសំណង់រូបវ័ន្ត បុគ្គលសិក្សាគម្រោងប្លង់ និងក្រុមជាងសំណង់នៃចំណុចទីIII-1ក្នុងសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ត្រង់លេខ១ ការចុះបញ្ជីលើកដំបូងសម្រាប់ក្រុមជាងសំណង់ ត្រូវបង់ចំនួន៨០០.០០០រៀល និងបន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ត្រូវបង់ចំនួន៦០០.០០០រៀល និងសារាចរណែនាំលេខ០០១ដ.ន.ស/អ.ស.ណា ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ត្រង់ចំណុចទី II បានចែងថា " សមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត/ក្រុង រួមមាន ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មឱ្យដល់ក្រុមជាងសំណង់ ចេញលិខិតបិទ ផ្អាកអាជីវកម្មក្រុមជាងសំណង់ ស្រង់ស្ថិតិសហគ្រាស ក្រុមហ៊ុន រួមទាំងក្រុមជាងសំណង់ និងក្រុមជាងតាមមុខជំនាញ ដែលធ្វើអាជីវកម្មក្នុងមូលដ្ឋានរបស់ខ្លួន តាមដាន ត្រួតពិនិត្យ គ្រប់គ្រងសកម្មភាពអាជីវកម្ម ត្រូវផ្អាក ឬបិទសកម្មភាពអាជីវកម្មរបស់

ក្រុមជាងសំណង់ណាដែលប្រកបអាជីវកម្មជួសជុល និងសាងសង់គ្មានលិខិតអនុញ្ញាតពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ឬករណីដែលក្រុមជាងសំណង់នោះមិនគោរពតាមការកំណត់ ការណែនាំ បទប្បញ្ញត្តិផ្សេងៗពីក្រសួង និងមន្ទីរខេត្ត-ក្រុងមានសមត្ថកិច្ច។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញពុំទាន់មានវិធានការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងស្រង់ស្ថិតិសកម្មភាពអាជីវកម្មរបស់ក្រុមជាងសំណង់ ព្រមទាំងធ្វើការប្រមូលចំណូលពីការប្រកបអាជីវកម្មសាងសង់របស់ក្រុមជាងសំណង់ ដែលមិនបានមកស្នើសុំចុះបញ្ជីប្រកបអាជីវកម្មជាក្រុមជាងសំណង់នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញឱ្យបានពេញលេញ និងត្រឹមត្រូវនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរធ្វើការណែនាំដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីឱ្យធ្វើការគ្រប់គ្រង និងប្រមូលចំណូលពីការចុះបញ្ជីក្រុមជាងសំណង់ប្រកបអាជីវកម្មឱ្យបានពេញលេញ និងមានប្រសិទ្ធភាពខ្ពស់ ។

ឆ្លើយតបនឹងករណីនេះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីបានឆ្លើយបំភ្លឺថា:

- យោងសារាចរណែនាំលេខ០០១ ដ.ន.ស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងក្រុមជាងសំណង់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមជាងសំណង់ភាគច្រើនស្នើសុំបង្កើតបានជាក្រុមហ៊ុនសំណង់ ដើម្បីមានសិទ្ធិដេញថ្លៃសាងសង់ទូទាំងប្រទេស។

- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញស្នើសុំធ្វើវិសោធនកម្មសិទ្ធិសាងសង់របស់ក្រុមជាងសំណង់ ឬលុបសិទ្ធិបង្កើតក្រុមការងារសំណង់នៅថ្នាក់មន្ទីរ។

ផ្អែកលើការបំភ្លឺនេះអាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងធ្វើការណែនាំដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីឱ្យធ្វើការគ្រប់គ្រង និងប្រមូលចំណូលពីក្រុមជាងសំណង់ដែលប្រកបអាជីវកម្មលើវិស័យសំណង់ឱ្យបានពេញលេញ និងប្រសិទ្ធភាព។

### ៣.១.៨. ការកត់ត្រាចំណូលមិនត្រឹមត្រូវតាមការិយបរិច្ឆេទ

ជារៀងរាល់ចុងឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតែចេញនូវសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយ និងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិ។ រាល់ចំណូលថវិកាថ្នាក់ជាតិទាំងអស់ ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំនីមួយៗ ជាកំហិត”។

តាមការធ្វើសវនកម្មបញ្ជីបេឡា និងបង្កាន់ដៃទទួលប្រាក់ពីការផ្តល់សេវាសាធារណៈក្នុងឆ្នាំ២០១៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសុខាភិបាលបានកត់ត្រាចំណូលមិនត្រឹមត្រូវតាមការិយបរិច្ឆេទ ដែលមានទឹកប្រាក់សរុបចំនួន៣៤២ ៨៩៣ ០០០រៀល ក្នុងនោះចំណូលទទួលបានក្នុងឆ្នាំ២០១៥មានចំនួន១៧៣ ៧០៥ ០០០រៀល បានកត់ត្រាជាចំណូលខែមករា ឆ្នាំ២០១៦ ហើយចំណូលដែលទទួលបានចុងឆ្នាំ ២០១៦ ចំនួន១៦៩ ១៨៨ ០០០រៀល កត់ត្រាជាចំណូលក្នុងខែមករា ឆ្នាំ២០១៧។

ការអនុវត្តផ្ទុយពីសារាចរខាងលើនេះ នាំឱ្យការកត់ត្រាតួលេខចំណូលមិនបានពេញលេញ និងទាន់ពេលវេលា។

ក្រសួងសុខាភិបាលបានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ និងបានបំភ្លឺថា នឹងខិតខំកែលម្អនៅឆ្នាំបន្តបន្ទាប់ទៀត។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.៩. ការរក្សាសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់

ប្រកាសលេខ០០១ សហវ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែលម្អនីតិវិធីអនុវត្តថវិកាត្រង់ចំណុច១-ក អំពីចំណូលបានចែងថា "ចំនួនសាច់ប្រាក់ដែលភ្នាក់ងារ ឬអង្គភាពនីមួយៗ អាចរក្សាទុកក្នុងបេឡារបស់ខ្លួនត្រូវបានកំណត់ត្រឹមចំនួនមិនឱ្យលើសពី២ ០០០ ០០០រៀល"។

តាមការពិនិត្យបញ្ជីបេឡាលើការកត់ត្រាប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ និងការរាប់សាច់ប្រាក់នៅក្រសួងសុខាភិបាល (រដ្ឋបាលកណ្តាល) និងតាមការពិនិត្យបញ្ជីបេឡា របាយការណ៍បង់ចំណូលចូលថវិការដ្ឋ និងធ្វើសារពើភណ្ឌសាច់ប្រាក់នៅអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា៖

- រដ្ឋទេយ្យករនៅក្រសួងសុខាភិបាលបានរក្សាទុកសាច់ប្រាក់ក្នុងបេឡាចំនួន ៣៧៨ ១០០ ០០០រៀល និង

- អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជាបានរក្សាសាច់ប្រាក់ចំណូលពីសេវាផ្សាយពាណិជ្ជកម្មចំនួន៤២ ០៣៣,៥៤ ដុល្លារអាមេរិក។

អាស្រ័យហេតុនេះ ក្រសួងគួរណែនាំដល់អង្គភាពក្រោមឱវាទអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងចំណុចនេះ ក្រសួងសុខាភិបាលបានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិលើករណីនេះ ហើយសន្យាថានឹងខិតខំអនុវត្តឱ្យបានល្អស្របតាមប្រកាសខាងលើនៅឆ្នាំក្រោយទៀត និងអគ្គនាយកដ្ឋានទូរទស្សន៍ជាតិបានបំភ្លឺថា ចំពោះរបាយការណ៍របស់អាជ្ញាធរសវនកម្មជាតិ ដូចខាងក្រោម៖

១. សាច់ប្រាក់ដែលនៅសេសសល់មួយចំនួនសន្សំទុកសម្រាប់បើកប្រាក់រង្វាន់ជូនមន្ត្រីរាជការនៅពេលបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិ ផ្តល់ជារង្វាន់លើកទឹកចិត្ត និងសម្រាប់ជួយឧបត្ថម្ភដល់មន្ត្រីដែលមានជំងឺ ឬជួបឧបទ្ទវហេតុនានាអំឡុងពេលបំពេញការងារ។

២. សាច់ប្រាក់មួយចំនួនទៀតតម្កល់ទុកសម្រាប់ចំណាយពេលមានករណីកើតឡើងដោយប្រការចៃដន្យណាមួយ(ដូចជាៈ សម្រាប់ជួសជុលឧបករណ៍បច្ចេកទេសផ្សេងៗ)។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១០. ការមិនទាន់បានប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្ម

ប្រកាសរួមលេខ១០០៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងព័ត៌មានស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព័ត៌មាន ត្រង់ប្រការ១ បានចែងថា "អនុញ្ញាតឱ្យក្រសួងព័ត៌មានអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ"។ តាមតារាងឧបសម្ព័ន្ធភ្ជាប់នៃប្រកាសរួមខាងលើនេះបានតម្រូវឱ្យក្រសួងព័ត៌មានប្រមូលចំណូលអំពីការអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយផ្សេងៗ ដូចជា "តាមប៉ាណូ តាមមធ្យោបាយដឹកជញ្ជូន តាមអាហ្វីស តាមភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម..."។

តាមការពិនិត្យរបាយការណ៍អនុវត្តចំណូលប្រចាំឆ្នាំ២០១៦ និងរបាយការណ៍ចំណូលដែលប្រមូលបានពីកម្រៃសេវាសាធារណៈប្រចាំឆ្នាំ២០១៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងព័ត៌មានមិនទាន់បានប្រមូលចំណូលពីការអនុញ្ញាតការផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូពាណិជ្ជកម្មតាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ ពាណិជ្ជកម្មតាមអាហ្វីស និងតាមភ្នាក់ងារផ្សាយពាណិជ្ជកម្មនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មានគួរអនុវត្តប្រកាសរួមលេខ១០០៣សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ឆ្លើយតបនឹងករណីនេះ ក្រសួងព័ត៌មានបានបញ្ជាក់ថា ករណីការប្រមូលចំណូលពីការអនុញ្ញាតផ្សព្វផ្សាយពាណិជ្ជកម្មតាមប៉ាណូពាណិជ្ជកម្ម តាមមធ្យោបាយដឹកជញ្ជូនផ្សេងៗ ពាណិជ្ជកម្មតាមអាហ្វីស និងតាមភ្នាក់ងារផ្សាយពាណិជ្ជកម្ម ដោយសារអតិថិជន និងអាជ្ញាធរមានសមត្ថកិច្ចយល់ពុំច្បាស់លាស់អំពីនីតិវិធី និងលិខិតបទដ្ឋាន ដែលចូលជាធរមានដែលកំពុងតែធ្វើការកែទម្រង់ជាញឹកញាប់របស់ក្រសួង-ស្ថាប័ន និងសមត្ថកិច្ចពាក់ព័ន្ធ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១១. ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម

ក្រសួងពាណិជ្ជកម្មបានចេញប្រកាស ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ការិយាល័យគ្រប់គ្រងអាជីវកម្មមានភារកិច្ចចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម និងចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មលោហធាតុ ត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការសម្រាប់ការិយបរិច្ឆេទ ២០១៦ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មនៅតាមបណ្តាអង្គភាពមួយចំនួន ដូចខាងក្រោម៖

- មន្ទីរពាណិជ្ជកម្មខេត្តតាកែវ បានចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មបានចំនួន ៧៥០ ក្នុងចំណោម ១ ០៥០
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ បានចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មបានចំនួន ៧១១ ក្នុងចំណោម ២ ៤៩២។

ដើម្បីប្រមូលចំណូលពីលិខិតអនុញ្ញាតធ្វើអាជីវកម្ម គ្រប់អង្គភាពពាក់ព័ន្ធ គួររួសរាន់ចុះត្រួតពិនិត្យទីតាំងអាជីវកម្មដ្ឋានឡើងវិញ។

ឆ្លើយតបនឹងការលើកឡើងនេះ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ បានឯកភាពតាមការលើកឡើង។ មន្ទីរពាណិជ្ជកម្មខេត្តតាកែវមានការខិតខំប្រឹងប្រែងចុះអនុវត្តទៅតាមផែនការដែលបានគ្រោងទុករបស់មន្ទីរ (បានអនុវត្តលើសផែនការចំណូលដែលបានគ្រោងក្នុងផែនការឆ្នាំ ប៉ុន្តែអនុវត្តប្រមូលចំណូលមិនអស់មូលដ្ឋានក្រុង ស្រុកទូទាំងខេត្តតាកែវ) បញ្ហានេះដោយសារសេវាករពាណិជ្ជករ មិនទាន់យល់ជ្រួតជ្រាបអំពីច្បាប់ស្តីពីវិធានពាណិជ្ជកម្ម។

ឆ្លើយតបនឹងការលើកឡើងនេះ មន្ទីរពាណិជ្ជកម្មខេត្តតាកែវ មានការខិតខំប្រឹងប្រែងចុះអនុវត្តទៅតាមផែនការដែលបានគ្រោងទុករបស់មន្ទីរ ចំណូលដែលបានអនុវត្តលើសផែនការគ្រោងក្នុងឆ្នាំ ប៉ុន្តែអនុវត្តប្រមូលមិនអស់មូលដ្ឋានក្រុង ស្រុកទូទាំងខេត្តតាកែវនេះ ដោយសារសេវាករពាណិជ្ជករ មិនទាន់យល់ជ្រួតជ្រាបអំពីច្បាប់ស្តីពីពាណិជ្ជកម្ម និងមិនសហការ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា គ្រប់អង្គភាពនឹងជំរុញការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មឲ្យបានពេញលេញ។

### ៣.១.១២. ភាពយឺតយ៉ាវក្នុងការទូទាត់ចំណាយពីការដកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី

ដើម្បីពង្រឹងការចំណាយថវិការដ្ឋឱ្យស្របបានត្រឹមត្រូវ និងស្របតាមគោលការណ៍ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/១៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៨ ត្រង់មាត្រា១១ បានចែងថា " ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់ថ្ងៃទី៣១ ខែធ្នូ" និងប្រកាសរួមលេខ៩៩៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ប្រការ៥ វាក្យខណ្ឌទី២ បានចែងថា " រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងត្រង់វាក្យខណ្ឌទី៣ ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិលើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្តតាមនីតិវិធីទូទាត់ជាប្រាក់បុរេប្រទាន..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ឆ្នាំង និងខេត្តប៉ៃលិន នៅមានភាពយឺតយ៉ាវក្នុងការទូទាត់ចំណាយពីការដកប្រាក់រង្វាន់លើកទឹកចិត្តពីសេវាសាធារណៈសម្រាប់ឧបត្ថម្ភមន្ត្រីរបស់ក្រសួង មន្ទីរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ និងចំណាយផ្សេងៗ ក្នុងឆ្នាំ២០១៦ មានដូចខាងក្រោម៖

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សរុបចំនួន៣ ៩០៥ ០០៥ ៤០០រៀល
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំងសរុបចំនួន ៤៥ ៧៤៧ ០០០រៀល
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តប៉ៃលិនសរុបចំនួន ១៤០ ១៨៧ ១៧៥រៀល។

ទន្ទឹមនឹងនេះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ ក៏បានយកថវិកាចំណាយសម្រាប់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន២០ ៧៤៤ ០០០រៀល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះចំនួន៥៨ ១៥១ ៨៧៨រៀលពីឆ្នាំ២០១៥មកធ្វើការទូទាត់តណាទានចំណាយសម្រាប់ប្រាក់រង្វាន់លើកទឹកចិត្តនៅក្នុងឆ្នាំ២០១៦។

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គួរធ្វើការទូទាត់ចំណាយប្រាក់រង្វាន់ឱ្យបានពេញលេញ និងទាន់ការិយបរិច្ឆេទនៃឆ្នាំ។

ឆ្លើយតបនឹងករណីនេះក្រសួង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់បានធ្វើការបញ្ជាក់ថាៈ

- ចំពោះការយឺតយ៉ាវក្នុងការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តពីកម្រៃសេវាសាធារណៈ គឺបណ្តាលមកពីចំណូលប្រមូលជាក់ស្តែងកើនឡើងលើសផែនការ ជាហេតុធ្វើឲ្យតណាទានដែលមាន

មិនគ្រប់សម្រាប់ការទូទាត់ចំណាយបុរេប្រទានរង្វាន់លើកទឹកចិត្ត ហើយការស្នើសុំឥណទានបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានការយឺតយ៉ាវធ្វើឱ្យក្រសួងមិនមានឥណទានទំនេរ ដើម្បីធ្វើការទូទាត់ក្នុងឆ្នាំបានទាន់ពេលវេលាដែលតម្រូវឱ្យលើកទៅឆ្នាំបន្ទាប់។

- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង:

ដោយសារចំណូលលើសផែនការ ទើបធ្វើឲ្យខ្វះឥណទាន ទើបមន្ទីរដនសសខេត្តកំពង់ឆ្នាំងយកថវិកាចំណាយប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០១៥ ចំនួន៤៥ ៧៤៧ ០០០រៀល (សែសិបប្រាំលានប្រាំពីររយសែសិបប្រាំពីរពាន់រៀលគត់) មកទូទាត់ចំណាយឥណទានប្រាក់រង្វាន់ លើកទឹកចិត្ត នៅក្នុងឆ្នាំ២០១៦វិញ។

- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់:

ដោយសារចំណូលលើសផែនការ ទើបធ្វើឲ្យខ្វះឥណទាន ទើបមន្ទីរដនសសខេត្តពោធិ៍សាត់ យកថវិកាចំណាយប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០១៥ចំនួន២០ ៧៤៤ ០០០រៀល (ម្ភៃលាន ប្រាំពីររយ សែសិបបួនពាន់រៀលគត់) មកទូទាត់ចំណាយឥណទានប្រាក់រង្វាន់លើកទឹកចិត្តនៅក្នុងឆ្នាំ២០១៦វិញ។

- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តប៉ៃលិន:

ដោយសារខ្វះឥណទានទើបមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តប៉ៃលិនយកថវិកាចំណាយប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០១៥ចំនួន១០០ ០០០ ០០០រៀល មកទូទាត់ឥណទានប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០១៦វិញ។

- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ:

ដោយសារខ្វះឥណទានទើបមន្ទីរដនសសខេត្តក្រចេះយកថវិកាចំណាយប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ ២០១៥ ចំនួន ៥៨ ១៥១ ៨៧៨រៀល (ហាសិបប្រាំបីលាន មួយរយហាសិបមួយពាន់ ប្រាំបីរយចិតសិបប្រាំបីរៀលគត់) មកទូទាត់ចំណាយឥណទានប្រាក់រង្វាន់លើកទឹកចិត្តនៅក្នុងឆ្នាំ២០១៦វិញ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ ប៉ៃលិន និងខេត្តក្រចេះនឹងធ្វើការចំណាយថវិកា និងទូទាត់ចំណាយថវិកាពីប្រាក់រង្វាន់លើកទឹកចិត្តឱ្យបានទាន់ពេលវេលាស្របតាមការិយបរិច្ឆេទនៃឆ្នាំ និងស្របតាមគោលការណ៍ហិរញ្ញវត្ថុសាធារណៈ។

**៣.១.១៣. ការអនុវត្តចំណាយមុនការសម្រេច និងឯកភាពពីប្រធានអង្គភាពថវិកា**

ក្នុងការពង្រឹងយន្តការចំណាយថវិការជ្ជទេយ្យបុរេប្រទានឱ្យមានភាពត្រឹមត្រូវ និងស្របតាមនីតិវិធីចំណាយ រជ្ជទេយ្យបុរេប្រទាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ផ្នែកទី២ ប្រការ១៥ បានចែងថា "ជាគោលការណ៍ រជ្ជទេយ្យបុរេប្រទានត្រូវចំណាយជាសាច់ប្រាក់ ដោយមានសក្ខីបត្របញ្ជាក់ត្រឹមត្រូវ។ មុននឹងធ្វើការចំណាយជាសាច់ប្រាក់ រជ្ជទេយ្យករបុរេប្រទានត្រូវស្នើសុំគោលការណ៍ចំណាយទៅអាណាប័ក ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។ ក្រោយពីទទួលបានគោលការណ៍ចំណាយ រជ្ជទេយ្យករបុរេប្រទានត្រូវអនុវត្តការទូទាត់ចំណាយ ដោយតម្រូវឱ្យអ្នកទទួលប្រាក់ចុះហត្ថលេខាបញ្ជាក់អំពីការបានទទួលប្រាក់គ្រប់ចំនួនលើសក្ខីប័ត្រ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់ បានយកថវិកា ចំណាយរជ្ជទេយ្យបុរេប្រទានកម្មវិធីមួយចំនួន សម្រាប់ចំណាយទៅលើដំណើរការកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាពតាមបណ្តានាយកដ្ឋាន ក្នុងការទិញសម្ភារ ផ្គត់ផ្គង់ ប្រើប្រាស់ ជួសជុល ប្រជុំ សិក្ខា សាលា និងបេសកកម្ម ដោយធ្វើការចំណាយមុនធ្វើការស្នើសុំគោលការណ៍ចំណាយ និងមិនបានធ្វើការ ស្នើសុំគោលការណ៍ចំណាយ និងសម្រេចពីប្រធានអង្គភាពថវិកាជាមុន។

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចធ្វើការចំណាយ ពុំទាន់បានត្រឹមត្រូវ និងមានតម្លាភាព។

ផ្អែកលើករណីខាងលើនេះ ក្រសួងបានបញ្ជាក់ថា:

- មន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុរបស់កម្មវិធីពុំបានទទួលការណែនាំឱ្យបានច្បាស់អំពី នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន និងហិរញ្ញវត្ថុដោយថវិកាទទួលយកមកអនុវត្តការងារមាន ការយឺតយ៉ាវ។ ម្យ៉ាងទៀតដើម្បីជៀសវាងការយឺតយ៉ាវក្នុងការអនុវត្តតាមផែនការនីមួយៗរបស់អនុ កម្មវិធី ទើបអនុកម្មវិធីចាំបាច់ត្រូវការចំណាយមុនទើបសុំធ្វើការទូទាត់ជាក្រោយ។

- ដោយសារថវិកាទទួលយកមកសម្រាប់ការអនុវត្តការងារមានការយឺតយ៉ាវ ដូចនេះ អនុកម្មវិធីចាំបាច់ត្រូវធ្វើការចំណាយជាមុនទើបស្នើសុំធ្វើការទូទាត់ជាក្រោយ ដើម្បីជៀសវាងការយឺត យ៉ាវក្នុងការអនុវត្តសកម្មភាពតាមផែនការប្រចាំឆ្នាំ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ធ្វើការចំណាយថវិការជ្ជទេយ្យបុរេប្រទានកម្មវិធី ឱ្យស្របតាមនីតិវិធីចំណាយតាមរជ្ជទេយ្យ បុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

### ៣.១.១៤. ការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០១៦

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្ម សាធារណៈ ដោយបានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងទៀងទាត់ តាមវិធីសាស្ត្រ និងពេលវេលានៃដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម ដូចមានចែងក្នុងផែនការលទ្ធ កម្មដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត (ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ) ដោយត្រូវជៀសវាងដាច់ខាតរាល់ការអូសបន្លាយពេលវេលា ក្នុង គោលបំណងគេចវេសពីការអនុវត្តវិធីសាស្ត្រលទ្ធកម្មដេញថ្លៃសាធារណៈពេញលេញ ដោយស្នើសុំ កាត់បន្ថយរយៈពេលផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ឬស្នើសុំអនុវត្តវិធីសាស្ត្រលទ្ធកម្ម ដោយឡែកដោយចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុន ឬជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋណាមួយ។

តាមការធ្វើតេស្តផែនការលទ្ធកម្មប្រចាំឆ្នាំ និងរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មរបស់ ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អាជ្ញាធរសវនកម្មជាតិពិនិត្យ ឃើញថា ក្រសួងស្ថាប័នចំនួន៩ និងរាជធានីខេត្តចំនួន១៣ បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ ខ្លួនលើសពីផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៦ដែលបានអនុម័តរួច។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមបញ្ជាក់ថា ការបំបែកគម្រោងរបស់ស្ថាប័នអនុវត្តលទ្ធកម្ម មួយចំនួនដែលបានអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ខ្លួនលើសផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៦ នេះគឺជាគម្រោងដែលស្ថិតនៅក្រោមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្មផ្ទាល់។ ម្យ៉ាងវិញទៀត

ការបំបែកគម្រោងភាគច្រើនគឺបណ្តាលមកពីក្រុមលទ្ធកម្មនៃអង្គភាពថវិកាដែលទើបបង្កើតថ្មី ពុំទាន់យល់ច្បាស់ពីនីតិវិធី និងបទប្បញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ ហើយឆ្នាំ២០១៦គឺជាឆ្នាំទី២នៃការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញសម្រាប់ក្រសួងចំនួន២៥ ដូចនេះអង្គភាពថវិកានៃក្រសួងថវិកាកម្មវិធីដែលបានបង្កើតឡើងមិនទាន់យល់ពីការរៀបចំផែនការលទ្ធកម្មបើទោះបីមានការបណ្តុះបណ្តាលក៏ដោយ។ ទន្ទឹមនោះដែរ មានសកម្មភាពកើតឡើងដោយចៃដន្យជាយថាហេតុមិនបានគ្រោងទុកជាមុន ឬត្រូវបានរាជរដ្ឋាភិបាលសម្រេចឱ្យអនុវត្តភ្លាមៗ ហើយជាតម្រូវការចាំបាច់ក្នុងការទិញដែលមិនអាចរៀបចំកែតម្រូវផែនការលទ្ធកម្មទាន់ពេលវេលា។ ចំពោះតម្រូវការទំនិញសម្ភារចាំបាច់ចុងឆ្នាំដោយត្រូវប្រើប្រាស់ថវិកាបានមកពីការសន្សំត្រូវអនុវត្តចំណាយទើបរៀបចំស្នើសុំកែសម្រួលផែនការលទ្ធកម្មជាក្រោយ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

### ៣.១.១៥. ការបំបែកគម្រោងលទ្ធកម្មសាធារណៈ

សារាចរណែនាំលេខ០០៧ សហវ.សរណន ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី៣ ″ មិនអនុញ្ញាតឱ្យមានការសម្របសម្រួលណាមួយដើម្បីបំបែក ឬអង្កន់គម្រោងធានាចំណាយឱ្យទៅជាគម្រោងតូចៗ តម្រូវតាមកម្រិតទឹកប្រាក់ដែលបានប្រគល់សម្រេចក្នុងការអនុវត្តកិច្ចលទ្ធកម្មឡើយ។ ករណីមានការបំបែក ឬ អង្កន់ធានាចំណាយលើមុខសញ្ញាតែមួយនោះ បុគ្គល ឬ ស្ថាប័នសមត្ថកិច្ចត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។‶

តាមការពិនិត្យលើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ២០១៦ និងសំណុំឯកសារគម្រោងលទ្ធកម្មនីមួយៗ ក្រសួងព័ត៌មានបានអនុវត្តគម្រោងលទ្ធកម្មចំនួន២៨ មានទឹកប្រាក់សរុប១០ ៧៨៦ ៩៧៨ ០០០រៀល ក្នុងនោះ ក្រសួងបានទិញសម្ភារបច្ចេកទេសចំនួន០៥ គម្រោងដែលមានទឹកប្រាក់ចំនួន២ ២៧០ ០០០ ០០០រៀល។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០១៦ ក្រសួងព័ត៌មានបានអនុវត្តកិច្ចលទ្ធកម្មសាធារណៈពុំស្របតាមនីតិវិធីលទ្ធកម្មសាធារណៈ ដោយក្រសួងបានបំបែកគម្រោងលទ្ធកម្មដែលមាន យថាប្រភេទដូចគ្នាឱ្យទៅជាគម្រោងតូចៗ ដើម្បីតម្រូវតាមកម្រិតទឹកប្រាក់ដែលបានប្រគល់សម្រេចក្នុងការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មានគួរធ្វើការណែនាំអង្គភាពស្ថិតក្រោមឱវាទឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខាងលើ។

ឆ្លើយតបនឹងចំណុចនេះ ក្រសួងព័ត៌មានទទួលស្គាល់ថាពិតជាមានការបំបែកគម្រោងកិច្ចលទ្ធកម្មដែលមានយថាប្រភេទដូចគ្នា ក៏ព្រោះតែសម្ភារៈមួយចំនួនធំ ក្រសួងត្រូវការជាចាំបាច់និងបន្ទាន់ដោយពុំអាចរង់ចាំការដេញថ្លៃប្រកួតប្រជែងជាសាធារណៈបាន ព្រោះការដេញថ្លៃប្រកួតប្រជែងជាសាធារណៈប្រើរយៈពេលយូរ។ ទោះជាយ៉ាងណា ក្រសួងបាននឹងកំពុងខិតខំអនុវត្តឱ្យត្រូវទៅតាមវិធីសាស្ត្រលទ្ធកម្មឱ្យបានប្រសើរឡើង។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១៦. ការពុំមានបញ្ជីបេឡាសម្រាប់កត់ត្រាតាមដានចំណូល-ចំណាយថវិកា

ដើម្បីជំរុញការតាមដានចំណាយ និងកត់ត្រាចំណាយឱ្យត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន ត្រង់ប្រការ២៥ បានចែងថា "បញ្ជីគណនេយ្យរបស់រជ្ជទេយ្យករបុរេប្រទានមានដូចខាងក្រោម បញ្ជីបេឡាសម្រាប់កត់ត្រានូវទឹកប្រាក់រជ្ជទេយ្យបុរេប្រទានដែលបានទទួលពីគណនេយ្យករសាធារណៈ ទឹកប្រាក់ដែលបានចំណាយ និងទឹកប្រាក់ដែលនៅសល់..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពុំទាន់មានបញ្ជីបេឡាសម្រាប់ធ្វើការកត់ត្រាតាមដានថវិកាចំណូល-ចំណាយថវិការជ្ជទេយ្យបុរេប្រទានកម្មវិធីប្រចាំថ្ងៃរបស់ខ្លួនឱ្យ បានត្រឹមត្រូវ និងស្របទៅតាមនីតិវិធីហិរញ្ញវត្ថុនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់គួរធ្វើការណែនាំដល់អគ្គនាយកដ្ឋានសំណង់ឱ្យធ្វើការកត់ត្រាតាមដានចំណូល-ចំណាយថវិការបស់ខ្លួននៅក្នុងបញ្ជីបេឡាឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

ឆ្លើយតបនឹងករណីនេះអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សូមធ្វើការបញ្ជាក់ថាៈ

១. ឆ្នាំ២០១៦ បញ្ជីបេឡាស្ថិតនៅក្នុងការចាត់ចែងជារួមរបស់អង្គភាពថវិកាក្នុងអគ្គនាយកដ្ឋានសំណង់ ដូច្នេះអនុកម្មវិធីនីមួយៗពុំបានធ្វើបញ្ជីបេឡាឡើយ។

២. ឆ្នាំ២០១៧ អនុកម្មវិធីនីមួយៗត្រូវបានបង្កើតជាអង្គភាពថវិកា ដូចនេះបានរៀបចំបញ្ជីបេឡាសម្រាប់ការគ្រប់គ្រងរួចហើយ។

### ៣.១.១៧. ភាពយឺតយ៉ាវក្នុងការរៀបចំផ្ទៀងផ្ទាត់របាយការណ៍សម្រេចទូទាត់ថវិកាចំណូលចំណាយប្រចាំឆ្នាំ

ដើម្បីជំរុញដល់ការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាចំណូល-ចំណាយប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញនូវសារាចរណែនាំលេខ០១២ សហវ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបិទបញ្ជីចំណូល-ចំណាយ និងធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៦ ត្រង់ចំណុចទី II បានចែងថា "ចំពោះក្រសួង ស្ថាប័នរដ្ឋបាលកណ្តាលត្រូវផ្ទៀងផ្ទាត់តួលេខចំណូល-ចំណាយថវិការបស់ខ្លួនជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានវិនិយោគ នាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល (ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស) និងមន្រ្តីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានត្រូវគ្នា ដើម្បីរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកា ដោយមានបញ្ចូលតួលេខចំណូល-ចំណាយថវិការបស់មន្ទីរជំនាញនានាក្រោមឱវាទនៅតាមរាជធានី-ខេត្ត រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ-នាយកដ្ឋានចំណូល-ចំណាយថវិកា និងអគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានីយកម្ម) ឱ្យបានមុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ជាកំហិត។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាៈ

- គិតមកត្រឹមថ្ងៃចុះធ្វើសវនកម្មថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញកិច្ចនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅមានភាពយឺតយ៉ាវក្នុង

ការរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាចំណូល-ចំណាយឆ្នាំ២០១៦ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយរតនាគារជាតិ។

- នៅដំណាច់ខែមេសា ឆ្នាំ២០១៧ ក្រសួងសុខាភិបាលមិនទាន់បានបញ្ចប់ការធ្វើរបាយការណ៍សម្រេចទូទាត់ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ នៅឡើយ។

- តាមការពិនិត្យលើរបាយការណ៍សម្រេចទូទាត់ថវិកាប្រចាំឆ្នាំ២០១៦ (សេចក្តីព្រាង) អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតមកទល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ក្រសួងព័ត៌មានពុំទាន់បានបូកសរុបរបាយការណ៍សម្រេចទូទាត់ថវិកាដើម្បីផ្ទៀងផ្ទាត់ជាមួយរតនាគារជាតិ។

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន គួរធ្វើការរៀបចំរបាយការណ៍បូកសរុបចំណាយថវិកាប្រចាំឆ្នាំឱ្យបានពេញលេញ ទាន់ពេលវេលា និងស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងករណីនេះ៖

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សូមធ្វើការបញ្ជាក់ថា ដោយក្រសួងអនុវត្តថវិកាកម្មវិធីពេញលេញ តាំងពីឆ្នាំ២០១៥ ហើយក្រសួងត្រូវបូកសរុបរបាយការណ៍សម្រេចទូទាត់របស់ថ្នាក់កណ្តាល និងមន្ទីររៀបចំដែដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តទាំង ២៥ ការទូទាត់ថវិកា ឆ្នាំ២០១៦ គឺទូទាត់រហូតដល់ត្រីមាសទី១ឆ្នាំ២០១៧។ បច្ចុប្បន្នក្រសួងបានរៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាចំណូល ចំណាយ ឆ្នាំ២០១៦ រួចហើយ។

- ក្រសួងសុខាភិបាលសូមទទួលយកករណីនេះ និងសូមធ្វើការបកស្រាយថា ជារៀងរាល់ចុងខែកុម្ភៈ ក្រសួងសុខាភិបាលបានរៀបចំព្រាងរបាយការណ៍បូកសរុបចំណូល-ចំណាយ ដាក់ជូនទៅរតនាគារជាតិ ដើម្បីធ្វើការផ្ទៀងផ្ទាត់ តែត្រូវរង់ចាំរតនាគារជាតិធ្វើការបូកសរុបជម្រះអាណត្តិទាំងអស់ទើបធ្វើការផ្ទៀងផ្ទាត់បាន ចំពោះចំណូលក៏ដូច្នេះដែរ មិនថានៅរដ្ឋបាលកណ្តាល ឬតាមមន្ទីរសុខាភិបាលរាជធានី-ខេត្តនោះទេ។ ក្រោយពីទទួលបានអនុសាសន៍នេះ ក្រសួងនឹងណែនាំមន្ត្រីជំនាញឱ្យរៀបចំរបាយការណ៍បូកសរុបចំណូល-ចំណាយប្រចាំឆ្នាំរបស់ក្រសួងឱ្យបានរួចរាល់ជាមុន រីឯរបាយការណ៍ផ្ទៀងផ្ទាត់ជាមួយរតនាគារជាតិរៀបចំតាមភាពជាក់ស្តែង។

- ក្រសួងព័ត៌មានបានរៀបចំរបាយការណ៍សម្រេចទូទាត់រួចរាល់ ប៉ុន្តែត្រូវផ្ទៀងផ្ទាត់ជាមួយរតនាគារជាតិដើម្បីបិទបញ្ជីដែលជាហេតុធ្វើឱ្យមានការយឺតយ៉ាវ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១៨. ភាពយឺតយ៉ាវក្នុងការប្តូរស្លាកលេខរថយន្ត

ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រកបដោយប្រសិទ្ធភាព រាល់យានយន្តរបស់រដ្ឋទាំងអស់ត្រូវតែមានស្លាកលេខសម្គាល់ដែលជាកម្មសិទ្ធិរបស់រដ្ឋ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា បញ្ជីសារពើភណ្ឌរបស់គ្រឹះស្ថានអង្គរ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ មានរថយន្តចំនួន១១គ្រឿង ដែលមានទំហំតូចធំ ម៉ាកចំរុះ និងមានឆ្នាំផលិតចាប់ពីឆ្នាំ១៩៩៧ រហូតដល់ឆ្នាំ២០១២ សុទ្ធតែពាក់ស្លាកលេខកម្មសិទ្ធិឯកជនទាំងអស់ ដោយពុំទាន់បានប្តូរស្លាកលេខទាំងនោះ មកជាស្លាកលេខសម្គាល់កម្មសិទ្ធិរដ្ឋនៅឡើយ។

កត្តានេះ អាចនាំឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមានភាពធូររលុង និងអាចបាត់បង់ទ្រព្យសម្បត្តិរដ្ឋដោយប្រការណាមួយ ដូច្នេះ គ្រឹះស្ថានអង្គរត្រូវរួសរាន់រៀបចំប្តូរស្លាកលេខរថយន្តខាងលើ ឱ្យទៅជាស្លាកលេខសម្គាល់កម្មសិទ្ធិរបស់រដ្ឋ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ចំពោះករណីនេះ គ្រឹះស្ថាន បាននិងកំពុងរៀបចំបែបបទផ្ទេរកម្មសិទ្ធិរថយន្តទាំង១១គ្រឿងនេះរួចហើយ តាមរយៈលិខិតលេខ ០៣១គសអ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ របស់គ្រឹះស្ថានអង្គរ។

### ៣.១.១៩. បំណុលកើនឡើងដោយមិនមានវិធានការតឹងទារ

បទបញ្ជាលេខ០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ ចែងថា "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដាក់ចេញវិធានការជាមួយក្រសួង ស្ថាប័នសាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារបំណុលដែលផ្នែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋ ដូចជា បញ្ឈប់ការអនុញ្ញាតនាំចូល-នាំចេញ បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាប័ណ្ណ និងក្នុងករណីការអនុវត្តតឹងទារបំណុលនេះមិនមានប្រសិទ្ធភាព ក្រសួង ស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការ"។

តាមការពិនិត្យតារាងតាមដានបំណុលត្រូវទារប្រចាំឆ្នាំ និងរបាយការណ៍ចំណូលប្រចាំឆ្នាំ ២០១៥ និង២០១៦របស់អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ និងអគ្គនាយកដ្ឋានទូរទស្សន៍ជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងព័ត៌មាននៅមានបំណុលដែលមិនទាន់បានទារ ដូចខាងក្រោម៖

- អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៅមានបំណុលត្រូវទារគិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ មានទឹកប្រាក់សរុបចំនួន ៣០៧ ៥០០ ០០០ រៀល
- អគ្គនាយកដ្ឋានទូរទស្សន៍ជាតិនៅមានបំណុលត្រូវទារគិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ មានទឹកប្រាក់សរុបចំនួន ១២៨ ៧២៤ ០០០រៀល (៣២ ១៨១ ដុល្លារអាមេរិក)។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មានគួរចាត់វិធានការឱ្យបានម៉ឺងម៉ាត់ទារបំណុលពីសេវាសោតទស្សន៍ដែលបណ្តាស្ថានីយ៍វិទ្យុទូរទស្សន៍ទាំងអស់មិនទាន់បានបង់ឱ្យចូលខ្លួនមកបង់ឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

ចំពោះករណីនេះ ក្រសួងព័ត៌មានបានបញ្ជាក់ថា ក្រសួងព័ត៌មានចេញលិខិតក្រើនរំលឹកដល់អតិថិជនទាំងអស់ឱ្យអនុវត្តបង់ថ្លៃសេវាសោតទស្សន៍ជាបន្តបន្ទាប់ ហើយក្រសួងក៏បានចេញនូវលិខិតទារបំណុលពីអតិថិជនជារៀងរាល់ឆ្នាំផងដែរ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

## ៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១. ការប្រមូលពន្ធប្រថាប់ត្រា

ដើម្បីឱ្យការប្រមូលពន្ធប្រថាប់ត្រាលើអចលនទ្រព្យមានភាពសុក្រឹត្យ តម្រូវឱ្យម្ចាស់អចលនទ្រព្យ បំពេញ និងផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ និងពេញលេញជូនរដ្ឋបាលសារពើពន្ធ ដូចជា ដីកាបញ្ជូនរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ព័ត៌មានក្បាលដី វិញ្ញាបនប័ត្រ

សម្គាល់ម្ចាស់អចលនទ្រព្យ ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកផ្ទេរសិទ្ធិ និងអ្នកទទួលសិទ្ធិ លទ្ធផលស្តីពីការចុះត្រួតពិនិត្យទីតាំង គំនូសប្លង់ទីតាំង និងលិខិតប្រកាសពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ។ ប៉ុន្តែ តាមការពិនិត្យសំណុំឯកសារប្រថាប់ត្រាលើអចលនទ្រព្យចំនួន៤៧៦ ក្នុងខែមករា និងខែធ្នូ សម្រាប់ការិយបរិច្ឆេទ២០១៦ របស់សាខាពន្ធដារខេត្តមួយ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្តមិនមានព័ត៌មានដែលជាមូលដ្ឋានសម្រាប់ធ្វើការគណនាពន្ធប្រថាប់ត្រានេះឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ ដូចជា មិនបានបញ្ជាក់អំពីអាយុកាលសំណង់ រូបថតទីតាំង និងការកំណត់ប្រភេទអចលនទ្រព្យ។

ការមិនបានបំពេញ និងផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ និងពេញលេញចំពោះការបង់ពន្ធប្រថាប់ត្រាលើអចលនទ្រព្យនាំឱ្យមានការលំបាកក្នុងការគណនាប្រាក់ពន្ធឱ្យបានត្រឹមត្រូវ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអង្គភាពពន្ធដារឱ្យពង្រឹងការត្រួតពិនិត្យភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃឯកសារគាំទ្រ ដើម្បីធានាភាពត្រឹមត្រូវនៃការប្រមូលពន្ធប្រថាប់ត្រា។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា ករណីការដាក់លិខិតប្រកាសពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលបំពេញព័ត៌មានមួយចំនួនដោយអ្នកជាប់ពន្ធនៅមិនទាន់បានពេញលេញ ដូចជាមិនបានបញ្ជាក់អំពីអាយុកាលសំណង់ រូបថតទីតាំង និងការកំណត់ប្រភេទអចលនទ្រព្យ។ បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដោយមានការគណនាប្រាក់ពន្ធដោយស្វ័យប្រវត្តិផ្អែកលើគំនូសបង្ហាញទីតាំងអចលនទ្រព្យដែលមានការបញ្ជាក់ជាផ្លូវការពីរដ្ឋបាលសុរិយោដី។ បន្ថែមពីនេះទៀត អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលសុរិយោដី ក្នុងគោលបំណងពង្រឹងការប្រមូលពន្ធប្រថាប់ត្រាឱ្យកាន់តែមានប្រសិទ្ធភាពមួយកម្រិតទៀត ជាពិសេសការប្រមូលពន្ធប្រថាប់ត្រាលើអចលនទ្រព្យ ដែលពុំទាន់បានចុះបញ្ជី។

អាជ្ញាធរសវនកម្មជាតិបានឃើញការបំភ្លឺនេះ។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានការអនុវត្តកែលម្អនេះ។

### ៣.២.២. ការចេញវិញ្ញាបនប័ត្របញ្ជាក់អនាម័យពុំទាន់អស់លទ្ធភាព

ប្រកាសលេខ ៣០៨ អ.ប.ស/ធ.ព.ស ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង ត្រង់ប្រការ ១៧ បានកំណត់ថា ការិយាល័យគ្រប់គ្រងឱសថ និងសុវត្ថិភាពចំណីអាហារទទួលបន្ទុករៀបចំផែនការ អនុវត្តគោលនយោបាយជាតិ និងពិនិត្យបែបបទស្តីពីការងារគ្រប់គ្រងឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងលិខិតលេខ ០៦៥២ អសប/ឱអបស ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្ទេរសិទ្ធិជូនមន្ទីរសុខាភិបាលរាជធានី-ខេត្ត ក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់លើអនាម័យ និងការផ្តល់ស្លាកសញ្ញា (Logo) ជូនដល់ភោជនីយដ្ឋាន និងអាហារដ្ឋានគ្រប់ប្រភេទ ដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃរាជធានី-ខេត្តរបស់ខ្លួន"។

តាមរយៈរបាយការណ៍បូកសរុបអនាម័យចំណីអាហារតាមភោជនីយដ្ឋាន និងអាហារដ្ឋានឆ្នាំ២០១៦ របស់មន្ទីរសុខាភិបាលខេត្តចំនួន៤ខេត្ត ឃើញថា ពុំទាន់មានវិញ្ញាបនបត្របញ្ជាក់អនាម័យនៅឡើយ ក្នុងនោះ ខេត្តសៀមរាបមានចំនួន១៣៥ទីតាំង ខេត្តបន្ទាយមានជ័យ គ្រប់ទីតាំងទាំងអស់

ដែលស្ថិតិអាជីវកម្មដ្ឋានមិនត្រូវបានមន្ទីរស្រង់ឡើយ ខេត្តរតនគិរីមានចំនួន៣៤ទីតាំង និងខេត្តឧត្តរមានជ័យមានចំនួន៤២ទីតាំង។

ដោយសារការមិនពិនិត្យ និងបញ្ជាក់លើអនាម័យចំណីអាហារនៅតាមភោជនីយដ្ឋាន និងអាហារដ្ឋាន នាំឱ្យចំណីអាហារអាចពុំមានអនាម័យគ្រប់គ្រាន់ធ្វើឱ្យកើតមានជំងឺប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត ត្រូវជំរុញមន្ទីរសុខាភិបាល និងសមត្ថកិច្ចពាក់ព័ន្ធឱ្យមានកិច្ចសហការជាមួយម្ចាស់ភោជនីយដ្ឋាន និងអាហារដ្ឋាន ដើម្បីទទួលបានការត្រួតពិនិត្យអនាម័យចំណី ព្រមទាំងទទួលបានចំណូលថវិការដ្ឋផងដែរ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះបានយល់ស្រប ហើយសន្យាថានឹងណែនាំមន្ទីរសុខាភិបាលឱ្យអនុវត្តតាមប្រកាសណែនាំ។ រីឯរដ្ឋបាលខេត្តខ្លះទៀតថា មកពីខ្វះកិច្ចសហការគ្នារវាងមន្ទីរសុខាភិបាល និងមន្ទីរទេសចរណ៍។ មន្ទីរសុខាភិបាលបានពន្យល់ថា មុនពេលផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ជូនម្ចាស់ភោជនីយដ្ឋាន និងអាហារដ្ឋាន មន្ទីរទេសចរណ៍គួរតម្រូវឱ្យមានភ្ជាប់វិញ្ញាបនបត្របញ្ជាក់អនាម័យផងដែរ ព្រោះមន្ទីរទេសចរណ៍មានសិទ្ធិធ្វើអធិការកិច្ច និងធ្វើចំណាត់ថ្នាក់អនុលោមតាមបទដ្ឋានស្តង់ដារទេសចរណ៍នៅអាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍ ហើយភាគច្រើននៃអាជីវករមិនមកធ្វើតាមការណែនាំទេ ដោយប្រាប់មកក្រុមការងារថា មានច្បាប់អនុញ្ញាតពីមន្ទីរទេសចរណ៍រួចហើយ ភោជនីយដ្ឋានរបស់គាត់មានអនាម័យល្អ និងមានភ្ញៀវចូលច្រើនហើយ ដូច្នេះហើយមិនចាំបាច់យកវិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារពីមន្ទីរសុខាភិបាលធ្វើអ្វីទៀតទេ។

### ៣.២.៣. ការប្រមូលចំណូលពីការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុលពុំទាន់អស់លទ្ធភាព

អនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃ តម្លើងយានយន្ត ត្រង់ប្រការ៦ បានកំណត់នូវទំហំយានដ្ឋានអតិបរមាត្រឹម២៥០ម៉ែត្រការ៉េ ត្រូវមានការអនុញ្ញាតឱ្យធ្វើអាជីវកម្មយានដ្ឋានជួសជុល និងកែច្នៃ តម្លើងយានយន្តពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង។

តាមរយៈរបាយការណ៍ឆ្នាំ២០១៦ របស់ការិយាល័យគ្រប់គ្រងយានដ្ឋាន នៃមន្ទីរសាធារណការ និងដឹកជញ្ជូនចំនួន៦ខេត្តឃើញថា មានយានដ្ឋានមួយចំនួនមិនទាន់បានប្រមូលចំណូលពីការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនៅឡើយ ក្នុងនោះ ៖

ខេត្តសៀមរាបមានចំនួន ១៤ទីតាំង ខេត្តព្រះសីហនុមានចំនួន៣០ទីតាំងពុំបានសុំបន្តសុពលភាព ខេត្តបន្ទាយមានជ័យមានចំនួន៣១ទីតាំង ខេត្តរតនគិរីមានចំនួន៤៤ទីតាំង ខេត្តឧត្តរមានជ័យមានចំនួន៤២ទីតាំង ខេត្តស្វាយរៀងមានចំនួន២៩ទីតាំង។

ដោយសារការខ្វះវិធានការពីមន្ទីរសាធារណការ និងដឹកជញ្ជូន និងខ្វះកិច្ចសហការពីម្ចាស់យានដ្ឋាន នាំឱ្យការប្រមូលចំណូលពីការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មពុំទាន់អស់លទ្ធភាព ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត ត្រូវជំរុញមន្ទីរសាធារណការ និងដឹកជញ្ជូនឱ្យសហការជាមួយម្ចាស់យានដ្ឋានទាំងនោះ ដើម្បីប្រមូលចំណូលពីការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋាន។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តមួយចំនួនបានបំភ្លឺថា នឹងជំរុញឱ្យមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តអនុវត្តតាមអនុក្រឹត្យខាងលើ។ រីឯរដ្ឋបាលខេត្តមួយចំនួនទៀតថា

ភាពអសកម្មលើនេះ ដោយសារឃានដ្ឋានខ្លះទើបនឹងកកើតថ្មី ខ្លះទៀតពុំមានវិស្វករជំនាញត្រឹមត្រូវ ទើបមន្ទីរមិនចេញលិខិតអនុញ្ញាតជូន ប៉ុន្តែទោះជាយ៉ាងនេះក្តីរដ្ឋបាលខេត្តក៏បានសន្យាថា នឹងជំរុញការចុះបញ្ជីនេះនៅខែបន្តបន្ទាប់។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងពិនិត្យតាមដានការអនុវត្តការងារនេះបន្តទៀត។

**៣.២.៤. ការអនុវត្តកិច្ចលទ្ធកម្ម និងការប្រគល់ទទួលចុងឆ្នាំរបស់រាជធានី ខេត្ត**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយបានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងទៀងទាត់តាមវិធីសាស្ត្រ និងពេលវេលានៃដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម ដូចមានចែងក្នុងផែនការលទ្ធកម្មដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត (ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ) ដោយត្រូវជៀសវាងដាច់ខាតរាល់ការអូសបន្លាយពេលវេលា ក្នុងគោលបំណងគេចវេះពីការអនុវត្តវិធីសាស្ត្រលទ្ធកម្មដេញថ្លៃសាធារណៈពេញលេញ ដោយស្នើសុំកាត់បន្ថយរយៈពេលផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ឬស្នើសុំអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែកដោយចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុន ឬជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋណាមួយ។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា គម្រោងចំណាយជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់រាជធានី ខេត្តចំនួន០៦ បានអនុវត្តវិធីសាស្ត្រលទ្ធកម្មចរចាថ្លៃជាមួយអង្គភាពរដ្ឋ ដោយការចុះកិច្ចសន្យាអនុវត្តការងារវិញធ្វើនៅថ្ងៃទី៣០ខែធ្នូឆ្នាំ២០១៦ ហើយការប្រគល់ទទួលបញ្ចប់ការងារ១០០%វិញក៏ធ្វើនៅថ្ងៃដដែល។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមបំភ្លឺថា គម្រោងចំណាយជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់រាជធានីខេត្តចំនួន០៦ដែលទទួលបានឥណទានបន្ថែមពីថវិកាអតិរេកចុងឆ្នាំបានស្នើសុំអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែក "ការចរចាថ្លៃជាមួយអង្គភាពជំនាញរបស់រដ្ឋ"។ អង្គភាពជំនាញរបស់រដ្ឋបានចាប់ផ្តើមអនុវត្តការងារបន្ទាប់ពីទទួលបានថវិកាបុរេប្រទាន និងគោលការណ៍អនុញ្ញាតឱ្យអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចទើបអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាបន្តបន្ទាប់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ៨៦៤ សហវ.ប្រកចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ២០១៦ដោយអនុញ្ញាតឱ្យរាជធានី-ខេត្តអាចយោងសមតុល្យថវិកាអតិរេកទៅឆ្នាំបន្ទាប់។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានមើលនូវវឌ្ឍនភាពបន្តទៀត។

**៣.២.៥. ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ**

ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុច V បានកំណត់ថា របាយការណ៍សមិទ្ធកម្មទាំងអស់ត្រូវរៀបចំ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) តាមការិយបរិច្ឆេទ ដូចខាងក្រោម៖

- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស ត្រូវផ្ញើជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរបំផុត ១៥ថ្ងៃ បន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវផ្ញើជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

តាមរយៈការចុះសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកានៃមន្ទីរជំនាញមួយចំនួនក្នុងខេត្តចំនួន៦ ពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំឡើយ ក្នុងនោះ៖

១. ខេត្តសៀមរាបមានចំនួន ៣ មន្ទីរគឺមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរសាធារណការ និងដឹកជញ្ជូន និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

២. ខេត្តព្រះសីហនុមាន ៧ មន្ទីរ គឺមន្ទីរធនធានទឹក និងឧតុនិយម មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរទេសចរណ៍ មន្ទីរសុខាភិបាល មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៣. ខេត្តបាត់ដំបងមានចំនួន៩មន្ទីរគឺ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរពាណិជ្ជកម្ម មន្ទីរទេសចរណ៍ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរបរិស្ថាន មន្ទីរសុខាភិបាល មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរកិច្ចការនារី

៤. ខេត្តរតនគិរីមានចំនួន៤មន្ទីរ គឺមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរសុខាភិបាល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៥. ខេត្តឧត្តរមានជ័យមានចំនួន២មន្ទីរ គឺមន្ទីរកិច្ចការនារី និងមន្ទីរធនធានទឹក និងឧតុនិយម

៦. ខេត្តស្វាយរៀងមានចំនួន ៥មន្ទីរ គឺ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដោយសារការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ នាំឱ្យពុំមានសក្ខីកម្មក្នុងការវាស់វែងនូវប្រសិទ្ធផលនៃការអនុវត្តថវិកាតាមកម្មវិធី។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តត្រូវជំរុញមន្ទីរជំនាញទាំងនោះអនុវត្តឱ្យបានសមស្របតាមប្រកាសណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តមួយចំនួនបានឯកភាព និងជំរុញការអនុវត្តការងារនេះ។ រីឯរដ្ឋបាលខេត្តខ្លះទៀតបំភ្លឺថា មន្ទីរមួយចំនួនបានរៀបចំរួចហើយ ខ្លះទៀតពុំទាន់ទទួលបានគំរូរបាយកាណ៍។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៦. កង្វះខាតក្នុងការរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ

រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរណែនាំលេខ០៧ សរ ចុះថ្ងៃ៣០ ខែមិថុនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ទម្រង់ទី២ បានចែងថា តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗក្នុងចន្លោះ រយៈពេល០៥ (ប្រាំ) ឆ្នាំ នៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗ ដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តាមរយៈការចុះធ្វើសវនកម្មក្នុងអំឡុងពេលចាប់ពីខែមីនា ដល់ចុងឆ្នាំ២០១៧ នៅខេត្តបាត់ដំបង កោះកុង និងខេត្តកំពង់ធំ ឃើញថា សាលាខេត្ត និងមន្ទីរជំនាញមួយចំនួនក្នុងខេត្តនៅមិនទាន់បានរៀបចំតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៦ នៅឡើយ ក្នុងនោះខេត្តបាត់ដំបងមានចំនួន១៤តារាង ខេត្តកោះកុងមានចំនួន១០តារាង និងខេត្តកំពង់ធំមានចំនួន០៧តារាង។

ដោយសារការមិនបានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះប្រចាំឆ្នាំនេះ នាំឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមិនបានល្អ និងអាចបាត់បង់ជាយថាហេតុ។ ដូចនេះ សាលាខេត្ត និងមន្ទីរដែលពុំទាន់បានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ គួរខិតខំរួសរាន់រៀបចំតារាងខាងលើឱ្យបានឆាប់។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តមួយចំនួនបានទទួលយកអនុសាសន៍សវនកម្ម និងមួយចំនួនទៀតបញ្ជាក់ថា ក្រោយពីការធ្វើសវនកម្ម អង្គភាពមួយចំនួនបានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះរបស់ខ្លួនរួចហើយ នៅសល់មួយចំនួនធ្វើមិនទាន់រួចនៅឡើយ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងធ្វើការតាមដានការអនុវត្តអនុសាសន៍នេះបន្តទៀត។

### ៣.២.៧. ភាពយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ ៣៨៤៤ សហវ.ទរ ចុះ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការរំលឹកការធ្វើប្លង់កម្មសិទ្ធិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បណ្តាក្រសួង ស្ថាប័ន និងខេត្ត ក្រុង ដោយធ្វើការក្រើនរំលឹកដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ព្រមទាំងបណ្តាមន្ទីរ និងសាលាខេត្ត ក្រុងទាំងអស់ត្រូវរៀបចំធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋដែលខ្លួនកំពុងកាន់កាប់ឱ្យបានឆាប់រហ័ស ដោយរួមសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គ្រប់ខេត្តក្រុងទាំងអស់។

តាមរយៈការធ្វើតេស្តសវនកម្មនៅខេត្តចំនួន១៣ ឃើញថា ដីធ្លី ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សាលាខេត្ត និងមន្ទីរជំនាញមួយចំនួន ពុំទាន់មានប្លង់កម្មសិទ្ធិនៅឡើយ។

ដោយសារការយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើដីធ្លីរបស់រដ្ឋ និងការគ្រប់គ្រងដីរដ្ឋមិនបានល្អ បណ្តាលឱ្យកើតមានអំពើរំលោភបំពានពីមជ្ឈដ្ឋានខាងក្រៅ និងឈានដល់ការបាត់បង់ទ្រព្យសម្បត្តិរដ្ឋជាយថាហេតុ។

ហេតុដូចនេះ សាលាខេត្ត និងមន្ទីរជុំវិញខេត្តដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវរួសរាន់រៀបចំធ្វើប្លង់កម្មសិទ្ធិឱ្យបានឆាប់រហ័ស។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តមួយចំនួនបានបញ្ជាក់ថា ដីធ្លីមួយចំនួនបានទទួលប្លង់កម្មសិទ្ធិរួចហើយក្រោយពីការចុះធ្វើសវនកម្ម និងមួយចំនួនទៀតបានបំភ្លឺថា ការយឺតយ៉ាវនេះគឺបណ្តាលមកពីដីមានពាក់ព័ន្ធទំនាស់ និងការរំលោភបំពាន និងដីខ្លះទៀតកំពុងត្រូវបានសមត្ថកិច្ចរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីកំពុងអនុវត្តដំណើរការការងាររៀបចំឯកសារ។

## ៤. ការពិនិត្យនៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៦ នាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួនដែលអាជ្ញាធរសវនកម្មជាតិ

បានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា ខិតខំអនុវត្តកែលម្អគួរឲ្យកត់សម្គាល់ និងកោតសសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

**៤.១. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ:** ច្បាប់ស្តីពីសារពើពន្ធបានកំណត់ឲ្យអ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ នោះអ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ...”។ តាមការធ្វើសវនកម្មសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន៧២ក្រុមហ៊ុន សហគ្រាស ក្នុងការិយបរិច្ឆេទ២០១៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន៥០ក្រុមហ៊ុនសហគ្រាស (ក្រុមហ៊ុនសហគ្រាសស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន១៤ និងស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធមធ្យមចំនួន៣៦) មិនបានកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ដែលជាហេតុនាំឱ្យរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ។ ករណីនេះ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានរៀបចំផែនការសកម្មភាព ដើម្បីកែលម្អ និងជំរុញឱ្យអ្នកជាប់ពន្ធកាន់កាប់បញ្ជីស្ទាមឱ្យបានត្រឹមត្រូវ ដោយបាន និងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាច្រើនដល់អ្នកជាប់ពន្ធនានា តាមវិស័យអាជីវកម្មសំខាន់ៗ ដើម្បីពន្យល់ណែនាំពីការកាន់បញ្ជីការគណនេយ្យឲ្យបានត្រឹមត្រូវ លើសពីនេះទៀតក៏បានចេញសេចក្តីជូនដំណឹងលេខ១២១៩ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការអនុគ្រោះលើកលែងទោសទណ្ឌនានាក្នុងការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត និងបានធ្វើការណែនាំដល់មន្ត្រីចាត់ចែងលិខិតប្រកាស និងសវនករគ្រប់រូបឱ្យយកចិត្តទុកដាក់ចំពោះការកាន់បញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធនៅពេលប្រកាស និងពេលចុះធ្វើសវនកម្ម និងបានបោះពុម្ពសៀវភៅណែនាំស្តីពីការកាន់កាប់ កត់ត្រាបញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសជាអ្នកជាប់ពន្ធតូច។

**៤.២. ការបំពេញកាតព្វកិច្ចសារពើពន្ធ:** ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធបានកំណត់ឲ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។ តាមការធ្វើសវនកម្មលើបញ្ជីឈ្មោះក្រុមហ៊ុន សហគ្រាសដែលបានចុះបញ្ជី និងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធចំពោះ លោក លោកស្រី នាយកក្រុមហ៊ុន សហគ្រាសនីមួយៗឲ្យមកដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំខែ ប្រចាំឆ្នាំនៅអង្គភាពពន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៦ មានក្រុមហ៊ុនមួយចំនួនមិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ២០១៦ទេ។ ករណីក្រុមហ៊ុនមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធនេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំក្រុមការងារ ដើម្បីចុះអង្កេតស្រាវជ្រាវសហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ បានមកចុះបញ្ជីពន្ធដារបានគ្រប់ៗគ្នា។ ទន្ទឹមគ្នានេះដែរ បាន និងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីវប្បធម៌នៃការបង់ពន្ធតាមរយៈកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងតាមរយៈគោលនយោបាយបញ្ជ្រាបវប្បធម៌បង់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារដែលតម្រូវឲ្យនាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត ខណ្ឌ រៀបចំសិក្ខាសាលាតាមវិស័យអាជីវកម្មជូនអ្នកជាប់ពន្ធ។

**៤.៣. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ:** សហគ្រាសវិនិយោគទាំងឡាយ ដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំសហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ។ ក្នុងឆ្នាំ២០១៦ តាមការធ្វើតេស្តលើសំណុំឯកសារមួយចំនួននៅនាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារដែលបានចុះធ្វើសវនកម្មលើ សហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យ ត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យចំនួន៣១ ឃើញមានសហគ្រាសចំនួន ៦ មានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ រីឯក្រុមហ៊ុនសហគ្រាសផ្សេងទៀតនៅពុំឃើញមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យឡើយ។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំសៀវភៅណែនាំស្តីពីការធ្វើសវនកម្មសហគ្រាស និងកំពុងជំរុញឲ្យអ្នកជាប់ពន្ធតាមវិស័យមួយចំនួនដែលស្ថិតក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺតម្រូវឲ្យមានរបាយការណ៍ហិរញ្ញវត្ថុពីស្នងការគណនេយ្យឯករាជ្យ។

**៤.៤. ការប្រើប្រាស់វិក្កយបត្រ:** តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឲ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម គឺត្រូវមានចុះលេខរៀងត្រឹមត្រូវឲ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេស ដូចជា ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ ប៉ុន្តែ អាជីវកម្មរបបស្វ័យប្រកាសមួយចំនួនបានប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់ត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជា វិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ..។ ការប្រើប្រាស់ ឬចេញវិក្កយបត្រដោយមិនបានបំពេញព័ត៌មានគ្រប់គ្រាន់អាចពុំបញ្ជាក់បានពីភាពត្រឹមត្រូវ និងអាចជះឥទ្ធិពលដល់ការប្រមូលពន្ធ និងការធ្វើសវនកម្ម។ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំផែនការសកម្មភាពសម្រាប់កែលម្អករណីនេះ បានណែនាំផ្សព្វផ្សាយអំពីការប្រើប្រាស់វិក្កយបត្រឱ្យបានសមស្របតាមបទប្បញ្ញត្តិ ដោយបានចេញសេចក្តីណែនាំថ្មីលេខ ១១២៧ អពដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស បានបោះពុម្ពការប្រើប្រាស់វិក្កយបត្រចែកជូនម្ចាស់សហគ្រាសទាំងអស់ បានចេញសេចក្តីណែនាំលេខ២១៦០៦ អពដ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់លេខរៀងវិក្កយបត្រ និងកំពុងពង្រឹងយន្តការនៃការប្រើប្រាស់វិក្កយបត្រនេះដល់មន្ត្រីទាំងអស់ ព្រមទាំងបានធ្វើសវនកម្មដោយមានទាំងការពិន័យទោសទណ្ឌចំពោះក្រុមហ៊ុនសហគ្រាសមួយចំនួនដែលប្រើប្រាស់វិក្កយបត្រមិនបានត្រឹមត្រូវ។

**៤.៥. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ:** ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួល

ខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធ ជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មសង្កេតឃើញថា ក្រុមហ៊ុន សហគ្រាសមួយចំនួនបានប្រកាសពន្ធមិនត្រឹមត្រូវ និងសមស្រប ដូចជា ប្រកាសបៀវត្សទាប និងគណនាពន្ធលើប្រាក់បៀវត្សខុស ប្រកាសចំណូលទាប គណនាអាករពិសេសខុស និងគណនាប្រាក់រំដោះពន្ធលើប្រាក់ចំណេញលើស មិនប្រកាសពន្ធប្រាក់រំដោះលើប្រាក់ចំណេញលើចំណូលពីការជួលទីតាំង ជួលបន្ទប់ និងចលនទ្រព្យ និងគណនាប្រាក់អាករបំភ្លឺសាធារណៈខុស។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញផែនការសកម្មភាពសម្រាប់កែលម្អ ដើម្បីពង្រឹងការត្រួតពិនិត្យលើលិខិតប្រកាសពន្ធដោយមានមន្ត្រីទទួលបន្ទុកពិនិត្យ និងណែនាំចំពោះក្រុមហ៊ុន សហគ្រាសដែលដាក់លិខិតប្រកាសមិនត្រឹមត្រូវ មិនគ្រប់ខ្ទង់ និងមិនគ្រប់និទ្ទេស ថែមទាំងជំរុញការធ្វើសវនកម្មលើលិខិតស្នាមដោយកំណត់ពន្ធឡើងវិញ ចំពោះក្រុមហ៊ុន សហគ្រាសដែលប្រកាសមិនប្រក្រតី និងកំពុងជំរុញការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីចាត់ចែងលិខិតប្រកាស។

**៤.៦. ការប្រមូលពន្ធអចលនទ្រព្យ:** គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបានតម្រូវឱ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ ការអនុវត្តប្រមូលពន្ធអចលនទ្រព្យនៅមានកម្រិតនៅឡើយ ដោយសារអ្នកជាប់ពន្ធមួយចំនួនមិនបានផ្តល់ព័ត៌មានអំពីអចលនទ្រព្យ មិនមកចុះបញ្ជីពន្ធអចលនទ្រព្យ មិនមកប្រកាសបង់ពន្ធលើអចលនទ្រព្យ និងអ្នកជាប់ពន្ធមួយចំនួនទៀតបានចុះបញ្ជីពន្ធអចលនទ្រព្យរួចហើយ ប៉ុន្តែមិនព្រមមកបង់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបន្តពង្រឹងការយកចិត្តទុកដាក់ប្រមូលពន្ធអចលនទ្រព្យ តាមរយៈយន្តការឃាត់ទុក មិនអនុញ្ញាតឲ្យបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមិនអនុញ្ញាតឲ្យចុះបញ្ជីពន្ធដារ ក្នុងករណីកម្មសិទ្ធិករមិនទាន់បានបង់ពន្ធអចលនទ្រព្យ។

**៤.៧. ការកត់ត្រាចំណូលថវិការដ្ឋ:** បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈកំណត់ថា ការកត់ត្រាចំណូលថវិកាត្រូវផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានរៀបចំបញ្ជូនទៅឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការផ្ទៀងផ្ទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលមួយចំនួនមិនត្រូវបានកត់ត្រាដោយផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កនៅឡើយ ដោយសារក្រសួង ស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ។ ករណីទាំងនេះពាក់ព័ន្ធនឹងប្រភេទចំណូលមួយចំនួនដែលបានកើតមាននៅពេលកៀកចុងឆ្នាំ ហើយជាប្រភេទចំណូលដែលគ្រាន់តែធ្វើនិយ័តកម្មតួលេខ ដូចជា ចំណូលពីកម្រៃរតនាគារ ចំណូលពីវិសមភាពបេឡា និងខ្ទង់ចំណូលមួយចំនួនទៀតនៅកៀកចុងឆ្នាំ និងចំណូលពីឈ្នួលទីតាំងដែលធនាគារជាតិនៃកម្ពុជាបានបញ្ជូនប្រកាសឥណទានមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិហើយ ប៉ុន្តែក្រសួង ស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ។

**៤.៨. ការទូទាត់ និងការកត់ត្រាចំណាយ:** ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបានកំណត់ឱសានវាទត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការបញ្ជូនអាណត្តិបើកប្រាក់មួយចំនួនតូចទៅអគ្គនាយកដ្ឋានរតនាគារជាតិនៅតែមានភាពយឺតយ៉ាវ ដែលបង្កឱ្យមានការលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំ។ អាជ្ញាធរសនវកម្មជាតិសង្កេតឃើញថា ជាទូទៅអាណត្តិដែលបានបញ្ជូនចេញពីអគ្គនាយកដ្ឋានថវិកា ក៏ដូចជាពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើទៅតាមកាលបរិច្ឆេទកំណត់ (ត្រឹមថ្ងៃទី៣១ ខែធ្នូ នៃ

ការិយបរិច្ឆេទ) ប៉ុន្តែអាណត្តិទាំងនោះត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិនៅក្រោយការិយបរិច្ឆេទកំណត់បិទបញ្ជី ដោយមានសក្ខីប័ត្រគ្រប់គ្រាន់ និងប្រើប្រាស់ឥណទានដែលនៅសល់ក្នុងឆ្នាំ២០១៦។

**៤.៩. ការផ្ញើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖** អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។ សារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២៤ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១ខែមេសា ខែកក្កដា ខែតុលា និងខែមករា។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៦ មានក្រសួង ស្ថាប័ន រាជធានី ខេត្ត និងសហគ្រាសសាធារណៈមួយចំនួននៅមិនទាន់បានផ្ញើនូវរបាយការណ៍អំពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ មកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៅឡើយ។

**៤.១០. ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ:** រដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗក្នុងចន្លោះរយៈពេល០៥(ប្រាំ)ឆ្នាំនៃឆ្នាំគោល។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនពុំបានអនុវត្តឲ្យបានពេញលេញតាមការតម្រូវខាងលើនេះទេ ដោយអង្គភាពមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។

**៤.១១. ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ:** រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៦ ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ បានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជាធ្វើឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច**៧%** នាំមកនូវចំណូលមធ្យមសម្រាប់ប្រជាជនម្នាក់ៗ ក្នុងមួយឆ្នាំ នាឆ្នាំ២០១៦ កើនឡើងដល់១ ៣០២ដុល្លារអាមេរិក។ អត្រាភាពក្រីក្របានធ្លាក់ចុះមកត្រឹម១៣,៥% គិតត្រឹមឆ្នាំ២០១៤ ធៀបនឹងឆ្នាំ២០០៤ មានប្រមាណ៥៣,២%។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយក

ចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល ចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឲ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឲ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។